# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ឆ្នាំទី ២៦ ខែកុម្ភៈ លេខ ២

ព.ស. ២៤៩៦ – គ.ស. ១៩៥៤

# កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយដំណើងខាងសាសនា និងអក្សរសាស្ត្រ

បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ.

ផ្នែកសាសនា — បញ្ជីរឿង — ទំព័រ


— អត្ថកថា ................ ព្រះមហា សេក៍រ- យ៉យ..... ៨៣

— រឿងព្រះអង្គុលិមាលត្ថេរ .......... លោក ប៊ូ-ប៊ូ ......... ៩២


ផ្នែកអក្សរសាស្ត្រ


— ការបណ្ដុះនិស្ស័យ (តមក)........ ព្រះមហាឧត្តមវិជ្ជា ប៊ុង-ប៉ម... ១០៣

— រឿងសាមកុក (តមក).......... ឧកញ៉ា ឡូ-កន......... ១១៦

— នាលះនឹងទមយន្តី (តមក).......... អ្នកស្រី ស្រ៊ុន—សារីយ៉ាន់ ... ១២៩

— ដំណើរអស្ចារ្យនៃលោក វ៉ាត្សូប៊ីយូយេ ... លោក វ៉ាយ-ប៊ុក ........ ១៣៥

— ដំណឹងតាមខ្យល់ក្នុងកន្តារៈ .......... លោក ផេង- ជ្រីវ ........ ១៤៧


កំណត់ទីនប្រវត្តិការណ៍


— ការប្រឡងប្រជែងទំនៀមទម្លាប់ខ្មែរ ..... ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ ...... ១៥៤



មួយឆ្នាំមាន ១២ សៀវភៅ — ដំឡៃជាវ ២០០ រៀល

# KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique.

## TABLE DES MATIÈRES

### PARTIE RELIGIEUSE


— Attakatha . . . . . . . . . . *Brah Maha SAU-YOI* . . . . . 83

— Histoire de Brah Angulimalatthera . . . . . . . . . . . *M. BOU-PO* . . . . . . . . . 92


### PARTIE LITTERAIRE


— Education morale (suite) . . *Vén. PEUNG-PAM* . . . . . . 103

— Histoire de SAMĂOK (suite) . . *Oknha NOU-KAN* . . . . . . 116

— Nala et Damayanti . . (suite) *Mme SRIN-SARIS-YANN* . . . 129

— Le Voyage extraordinaire de Vasiobioyé. . . . . . . . . *M. RAY-BUC* . . . . . . . . . 135

— Le Souffle du désert (suite) . *M. PHENG-CHRIV* . . . . . . 147


### NOTES ET CHRONIQUES


— Concours des Moeurs et Coutumes. . . . . . . . . . *Commission des Moeurs et Coutumes* . . . . . . . . 154



Prix d'abonnement annuel (comprenant 12 numéros): 200$00

# អត្ថកថា

## ព្រះមហា សៅរ៍-យ៉យ វត្តឧណ្ណាលោម

និស្សិតសាលាបាលីជាន់ខ្ពស់

រៀបរៀង

---

### នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

សូមនមស្ការចំពោះព្រះភគវន្តមុនីអរហំសម្មាសម្ពុទ្ធ ព្រះអង្គនោះ (ព្រមទាំងព្រះធម៌និងព្រះអរិយសង្ឃដោយសេចក្ដីគោរព) ។

ឱកាសនេះ អាត្មាភាពសូមសំដែងធម្មកថាតាមព្រះពុទ្ធដីកាក្នុងគម្ពីរសំយុត្តនិកាយថា នត្ថិ អត្តសមំ បេមំ "សេចក្ដីស្រឡាញ់អ្វីស្មើនឹងខ្លួនមិនមាន" ដើម្បីជាសណ្ដាប់នៃពុទ្ធសាសនិកជន ដូចមានសេចក្ដីតទៅនេះ ៖

សម្ដេចព្រះមហាមុនីបរមគ្រូទ្រង់សំដែងបញ្ជាក់អំពី "អត្តា" គឺខ្លួនរបស់មនុស្សក្នុងលោកថា "មនុស្សយើងគ្មានស្រឡាញ់អ្វីឲ្យប្រហែលនឹងខ្លួន ឬជាងខ្លួនទេ" ។

ពាក្យថា "អត្តា" នេះ មានបទវិគ្រោះថា សុខទុក្ខំ អទតិ: ខាទតីតិ អត្តា (ប្រែថា) សភាវៈដែលទំពារស៊ីនូវសុខនិងទុក្ខឈ្មោះថា "អត្តា" ។ អត្តានេះខ្មែរយើងប្រែថា ខ្លួន ហេតុដូច្នេះ ពាក្យថា

ខ្លួន មិនមែនអ្វីដទៃឡើយ គឺចិត្តនេះឯង. ព្រោះចិត្តតែងផ្ទែកសំងំនៅក្នុង
កាយ ហើយអាចគិតនូវអារម្មណ៍ផ្សេងៗ ដឹងថាស្រួល ឬមិនស្រួលបាន
ចំណែកអវយវៈតូចធំមានដៃនឹងជើងជាដើមហៅថា កាយ ឬរាងកាយ;
កាយហើយនឹងចិត្តទាំងពីរនេះ លុះតែអាស្រ័យគ្នានឹងគ្នាទើបអាចប្រព្រឹត្ត
ទៅបាន; ព្រោះហេតុនេះ គួរសន្និដ្ឋានថា «ការប្រជុំព្រមដោយ
កាយនឹងចិត្ត ហៅថា ខ្លួន» ។

ធម្មតាមនុស្សក្នុងលោកតែងស្រឡាញ់កាយនឹងចិត្ត ដែលលោក
សន្មតហៅថាខ្លួននេះឯង ជាងអ្នកដទៃ ឬជាងវត្ថុអ្វីៗគ្រប់យ៉ាង, កុំចាំ
បាច់និយាយដល់មនុស្សដែលមានរាងកាយល្អមាំមួននោះឡើយ ដោយ
ហោចទៅ សូម្បីមនុស្សដែលមានរាងកាយពិការជាទម្ងន់ មានកើតឃ្លង់
ឬខ្វាក់ខ្វិនជាដើម ក៏នៅតែស្រឡាញ់ខ្លួនឯងជាងអ្នកដទៃ ទោះបីស្វាមី
ភរិយាបងប្អូនកូនចៅ ឬទ្រព្យសម្បត្តិដែលមានដំឡៃ ដូចត្បូងពេជ្រ
មាសប្រាក់ជាដើម ដែលគេថាជាទីស្រឡាញ់នោះ ក៏គង់តែមិន
ស្រឡាញ់ស្មើនឹងខ្លួនដែរ; អ្នកដែលស្រឡាញ់របស់ទាំងនោះ ហើយ
ខំស្វែងរកដោយមិនគិតនឿយហត់ ក៏ព្រោះតែសេចក្ដីស្រឡាញ់ខ្លួន
ទើបបានស្វែងរកមកដើម្បីជាគ្រឿងជួយទំនុកបំរុងខ្លួននោះឯង, សេចក្ដី
នេះគួរជ្រាប ដូចមនុស្សក្នុងលោកទាំងមូលដែលនឹងធ្វើការងារអ្វីៗគ្រប់
យ៉ាង ក៏សុទ្ធតែប្រារព្ធខ្លួនឯងជាមុន ហើយទើបបានធ្វើតាមសេចក្ដីប៉ុនប៉ង

នោះ ឬតាមសេចក្ដីយល់ឃើញ ថាត្រូវធ្វើយ៉ាងណា គ្រប់ៗគ្នាទាំងអស់ ដូចកូនឈ្នួលដែលធ្វើការឲ្យគេ ក៏ព្រោះតែចង់បានថ្លៃឈ្នួល ពេទ្យដែលរក្សារោគឲ្យគេ ក៏ព្រោះតែចង់បានកំណល់រង្វាន់ ឬអ្នកដែលធ្វើអ្វីមួយក៏ព្រោះតែប្រាថ្នាផលប្រយោជន៍គឺទ្រព្យសម្បត្តិនិងយសបរិវារជាដើម ដើម្បីទំនុកបំរុងខ្លួនជាមុន ហើយទើបទំនុកបំរុងអ្នកដទៃដែលនៅអាស្រ័យនឹងខ្លួនជាខាងក្រោយ ។

សំដែងមកនេះ ដើម្បីបញ្ជាក់ឲ្យឃើញច្បាស់ថាធម្មតាមនុស្សក្នុងលោក តែងស្រឡាញ់ខ្លួនឯងជាងអ្នកដទៃ ។ ព្រោះហេតុនោះ បានជាព្រះសក្យមុនីជាម្ចាស់ទ្រង់ត្រាស់ទេសនាថា នត្ថិ អត្តសមំ បេមំ "សេចក្ដីស្រឡាញ់អ្វីស្មើនឹងខ្លួនមិនមានឡើយ" ។

មនុស្សទាំងពួងដែលធ្វើអ្វីៗដើម្បីផលប្រយោជន៍ណាមួយ ព្រោះតែស្រឡាញ់ខ្លួននោះក៏មែនពិតហើយ ប៉ុន្តែតាមធម្មតារបស់មនុស្សក្នុងលោកនេះ ច្រើនតែខ្វល់ខ្វាយក្នុងការងារដែលមានប្រយោជន៍ក្នុងបច្ចុប្បន្នទាន់ភ្នែកឃើញ មិនសូវខ្វល់ខ្វាយប្រយោជន៍ក្នុងជាតិខាងមុខឲ្យច្រើនផងទេ ។

មានជនបំពួកខ្លះ មិនស្វែងរកគុណធម៌សេចក្ដីល្អ សេចក្ដីត្រូវជាក់ខ្លួន គឺមិនធ្វើទាន មិនរក្សាសីលជាដើម។ល។ មិនតែប៉ុណ្ណោះអ្នកខ្លះថែមទាំងបណ្ដែតបណ្ដោយឲ្យកាយ វាចា ចិត្តប្រព្រឹត្តលង់ទៅតាមអំណាចបាបអកុសលលាមកអាក្រក់ មានសេចក្ដីលោភ សេចក្ដីក្រោធខឹង និងសេចក្ដី

វង្វេងកាន់ប្រមាំ ជាដើមទៀតផង ។ ជនបែបនេះ អ្នកប្រាជ្ញទាំងឡាយ មានព្រះពុទ្ធជាដើម ឲ្យឈ្មោះថាជាមនុស្សស្អប់ខ្លួន ធ្វើខ្លួនឲ្យដូចជាសឹកសត្រូវដល់ខ្លួនឯងវិញ ។

ព្រោះហេតុនេះឯង សាធុជនទាំងឡាយដែលជាបណ្ឌិតប្រកបដោយប្រាជ្ញា កាលបើជ្រាបច្បាស់ថា ខ្លួនជាទីស្រឡាញ់របស់ខ្លួនជាបំផុតហើយ គួរតែប្រញាប់ប្រញាល់កំចាត់បង់អកុសលធម៌ដែលមកគ្រាក់ឲ្យឃ្លាតចេញឆ្ងាយចាកសន្តាន គួរកុំបណ្តោយឲ្យលង់ខ្លួនទៅតាមអំណាចកិលេសធម៌ជាគ្រឿងសៅហ្មងចិត្ត គឺ លោភៈ ទោសៈ មោហៈ ឡើយ ។

ន័យមួយទៀត អ្នកដែលស្រឡាញ់ខ្លួន គួរតែប្រញាប់ស្វែងរកទីពឹង គឺបុណ្យកុសលមកដកល់ទុកក្នុងខ្លួនឲ្យឆាប់ៗ ឲ្យទាន់ជីវិតនៅរស់ ព្រោះជីវិតរបស់មនុស្សនិងសត្វទាំងឡាយ មិននៅឋិតថេរយឺនយូរប៉ុន្មានឡើយ មុខជានឹងដល់នូវសេចក្តីស្លាប់សាបសូន្យទៅយ៉ាងឆាប់រហ័ស បើជនណាមួយធ្វេសប្រហែស ឬយល់ខុសថា ខ្លួនមិនងាយនឹងស្លាប់ទេ ជននោះឯងក៏មុខជានឹងបណ្តែតបណ្តោយចិត្តឲ្យប្រព្រឹត្តធ្វើតែអំពើបាបអកុសល ឥតរវល់នឹងអំពើបុណ្យ មានឲ្យទាននឹងរក្សាសីលជាដើមឡើយ បើប្រសិនជាកំពុងតែធ្វេសប្រហែសដូច្នោះ ហើយជួនជាប្រទះលើពេលដែលសេចក្តីស្លាប់ត្រូវមកដល់ ក្នុងមរណសម័យនោះ

ទោះបីមានចិត្តប្រាថ្នាចង់ធ្វើការកុសលក៏មិនងាយនឹងធ្វើបាន ព្រោះចិត្តមិនធ្លាប់ជួបប្រទះនឹងបុណ្យកុសលដល់ម្ដងសោះ ។

ម្យ៉ាងទៀតសេចក្ដីស្លាប់នេះ ជាកំពូលនៃសេចក្ដីទុក្ខព្រួយយ៉ាងធំ ព្រោះវេលាដែលទៀបនឹងស្លាប់នោះ តែងមានសេចក្ដីលំបាកយ៉ាងខ្លាំងជាមុនបំផុតហើយទើបស្លាប់ បើយ៉ាងដូច្នេះ អ្នកដែលធ្វេសប្រហែសមិនចំសាងសន្សំបុណ្យកុសលមានទានសីលភាវនាជាដើម ទុកក្នុងចិត្តឲ្យបានច្រើនអំពីចម្ងាយឲ្យហើយទេ ធ្វើម្ដេចនឹងអាចសាងសន្សំបុណ្យក្នុងពេលដែលមានសេចក្ដីព្រួយដោយមរណៈមកគ្របសង្កត់នោះបាន ។ កាលបើមិនមានអំពើបុណ្យកុសលណាមួយមកជួយឧបត្ថម្ភគាំទ្រក្នុងពេលនោះហើយ មុខជានឹងខូចកំណើតដែលកើតជាមនុស្សនេះ អ្នកនោះឯងរមែងបែរមុខឆ្ពោះទៅកាន់ចតុរាបាយ គឺទៅកើតក្នុងនរក ឬប្រេតជាដើម កាលបើទៅកើតក្នុងអបាយនោះហើយ កម្រណាស់នឹងត្រឡប់មកកើតជាមនុស្សវិញបាន សមដូចព្រះពុទ្ធភាសិតថា ចិត្តេ សំកិលិដ្ឋេ ទុគ្គតិ បាដិកង្ខា "កាលបើចិត្តសៅហ្មងហើយ ទុគ្គតិក៏រមែងកើតប្រាកដ" បើទុកជាមិនចង់បាន មិនចង់ទៅកើត ក៏គង់តែគេចមិនផុត ជៀសវាងពុំរួចដែរ ។ ព្រោះហេតុនេះហើយបានជាយើងទាំងឡាយគួរតែស្ដាយកំណើតដែលកើតមកជាមនុស្សនេះឲ្យណាស់ ដ្បិតដែល

យើងបានមកកើតជាមនុស្សនេះមិនមែនងាយទេ   សឹងបានដោយកម្រក្រៃពេកណាស់  ដូចពុទ្ធភាសិតក្នុងគម្ពីរខុទ្ទកនិកាយថា:

កិច្ឆោ មនុស្សប្បដិលាភោ កិច្ឆំ មច្ចាន ជីវិតំ
កិច្ឆំ សទ្ធម្មស្សវនំ កិច្ឆោ ពុទ្ធានមុប្បាទោ

"កិរិយាដែលត្រឡប់មកកើតជាមនុស្ស ជារបស់ក្រ, ជីវិតគឺការរស់នៅរបស់សត្វទាំងឡាយ ជាធម្មជាតក្រ, ការស្តាប់ធម៌របស់សប្បុរសជាកិច្ចកម្រ, កិរិយាកើតឡើងរបស់ព្រះពុទ្ធជាម្ចាស់ទាំងឡាយ ជារបស់ក្រ" ។

ឥឡូវនេះ យើងទាំងឡាយបានកើតមកជាមនុស្ស ហើយមានជីវិតរស់នៅ ព្រមទាំងបានជួបប្រទះនឹងធម៌អាថ៌ដែលជាពាក្យប្រដៅយ៉ាងពិសេសនេះថែមទៀត ក៏ប្រហែលគ្នានឹងបានទាន់ព្រះពុទ្ធដែរ បានឈ្មោះថារួចអំពីសេចក្តីក្រទាំង ៤ យ៉ាងនោះហើយ គឺថាជាបុញ្ញលាភដ៏ប្រសើរបំផុតរបស់យើងទាំងឡាយ គួរតែខំប្រឹងធ្វើបុណ្យ មានឲ្យទាន រក្សាសីល ចំរើនភាវនា ព្រមទាំងរៀនសូត្រធម៌អាថ៌ឲ្យចេះចាំស្ទាត់ជាដើម យ៉ាងប្រញាប់គ្រាន់នឹងបានជាទីពឹងពំនាក់ក្នុងជាតិនេះនឹងជាតិខាងមុខតទៅ គួរកុំបណ្តែតបណ្តោយឲ្យខូចជាតិកំណើត ដែលកើតមកជាមនុស្សនេះឡើយ ។ ធម្មតាបុគ្គលដែលបានទូក ឬសំពៅនឹងរទេះមកហើយ មិនគួរនឹងទុកយាននេះឲ្យពុកផុយរលួយខូចចោលទទេ ។ គួរតែប្រញាប់ផុត

ទំនិញហើយចេញទៅជួញឲ្យមានកំរៃ សេចក្ដីនេះមានឧបមាយ៉ាងណា មានគួរនាជួបយើងទាំងឡាយ ដែលបានមកចាប់កំណើតជាមនុស្សហើយ មិនគួរបណ្ដោយឲ្យពងកាយ ចាស់ឈឺស្លាប់ខូចទៅទទេៗ គួរតែប្រញាប់ធ្វើបុណ្យកុសល ដើម្បីយករបស់ចំណេញ គឺសេចក្ដីសុខក្នុងជាតិនេះ និងជាតិខាងមុខដោយឆាប់រហ័ស ។

ម្យ៉ាងទៀត សាធុជនណាដែលបានកសាងសន្សំបុណ្យកុសល មានឲ្យទានរក្សាសីល ៥ សីល ៨ ជាដើម សាធុជននោះទើបឈ្មោះថាជាមនុស្សស្រឡាញ់ខ្លួន ហើយដុសខាត់សំអាតខ្លួនឲ្យស្អាត ; សេចក្ដីនេះដូចពុទ្ធភាសិត ក្នុងគម្ពីរខុទ្ទកនិកាយថា:

អត្តានញ្ចេ បិយំ ជញ្ញា រក្ខេយ្យ នំ សុរក្ខិតំ
តិណ្ណមញ្ញតរំ យាមំ បដិជគ្គេយ្យ បណ្ឌិតោ

"បើបណ្ឌិតដឹងខ្លួនថាខ្លួនជាទីស្រឡាញ់ គួររក្សាខ្លួននោះឲ្យល្អ គួរថែទាំសំអាតខ្លួនក្នុងវ័យទាំង ៣ វ័យណាមួយឲ្យបាន" ។

ឯវិធីនឹងថែទាំរក្សាខ្លួន ឬនឹងដុសខាត់ស្អិតស្អាងខ្លួនឲ្យស្អាតនោះ ដូចសេចក្ដីអធិប្បាយតទៅនេះ ។

បើជាគ្រហស្ថគួរធ្វើបុណ្យទាំងឡាយ មានឲ្យទានរក្សាសីល ៥ សីល ៨ ជាដើម តាមសមគួរនឹងកម្លាំងរបស់ខ្លួន, បើជាបព្វជិតគួរខ្វល់ខ្វាយធ្វើវត្តប្រតិបត្តិតូច-ធំ ឬខំយកចិត្តទុកដាក់ក្នុងការរៀនសូត្រធម៌វិន័យ

ឲ្យបេះចាំស្ងាត់ ហើយប្រព្រឹត្តឲ្យត្រឹមត្រូវ ៗ ធ្វើយ៉ាងនេះទើបហៅថា ថែរក្សាខ្លួន ព្រមទាំងស្អិតស្អាងឲ្យស្អាតល្អដោយពិត ; បើប្រសិនជាគ្រហស្ថមិនអាចធ្វើការកុសលក្នុងរវាងបឋមវ័យឲ្យសព្វគ្រប់បាន ព្រោះមានសេចក្តីខ្វល់ខ្វាយក្នុងការងារ, លុះចូលក្នុងមជ្ឈិមវ័យគួរកុំប្រហែសធ្វេសឡើយ គួរខំប្រឹងធ្វើឲ្យបាន ; បើប្រសិនជាក្នុងរវាងមជ្ឈិមវ័យរវល់ដោយកិច្ចការរបរចិញ្ចឹមជីវិតខ្លួននឹងកូនទៅ មិនអាចនឹងធ្វើការកុសលបានទេ លុះចូលដល់រវាងបច្ឆិមវ័យ គួរប្រឹងដំនះចិត្តធ្វើឲ្យខាងតែបានកុំឲ្យខាន, យ៉ាងនេះទើបហៅថាស្រឡាញ់ខ្លួនហើយបីបាច់រក្សាខ្លួនសំអាតខ្លួន, បើមិនធ្វើការកុសលគ្រប់វ័យទាំងអស់ មិនហៅថាស្រឡាញ់ខ្លួនឡើយ ត្រឡប់បានឈ្មោះថាស្អប់ខ្លួន ធ្វើខ្លួនឲ្យសូន្យបាកប្រយោជន៍វិញ ៗ

ឯចំណែកខាងបព្វជិត បើក្នុងបឋមវ័យរវល់នឹងរៀនសូត្រធម៌អាថ៌ ឬធ្វើជាអាចារ្យបង្រៀនសិស្សគណ ឬក៏រវល់នឹងធ្វើវត្តតូច-ធំ មានការបំរើឧបជ្ឈាយ៍អាចារ្យជាដើម ហើយធ្វេសប្រហែសមិនបានធ្វើសមណធម៌, លុះដល់ចូលក្នុងរវាងមជ្ឈិមវ័យគួរកុំប្រហែសឡើយ គួរខំចំរើនសមណធម៌ឲ្យបាន, បើប្រសិនជាក្នុងរវាងមជ្ឈិមវ័យរវល់រៀនបាលី នឹងអដ្ឋកថា ឬរវល់នឹងវិនិច្ឆ័យកាត់សេចក្តីខុសត្រូវឲ្យគេ ឬក៏រវល់នឹងដោះស្រាយអាថ៌ប្រស្នា ហើយក៏ធ្វេសប្រហែសទៅខ្លះ លុះចូលដល់បច្ឆិមវ័យ

គួរចំធ្វើសមណធម៌កុំឲ្យខាន បើបានធ្វើទើបឈ្មោះថា ស្រឡាញ់ខ្លួន រក្សាខ្លួន សំអាតខ្លួនឲ្យស្អាតល្អ ។

អាត្មាភាពសំដែងធម៌ទេសនាមកនេះ សមគួរដល់កាលវេលានឹងបញ្ចប់តែប៉ុណ្ណោះ ។ សូមជូនពរដល់ពុទ្ធបរិស័ទ សូមឲ្យបានប្រកបដោយឥដ្ឋមនុញ្ញផលវិបុលសុខគ្រប់ប្រការ ! ។

ទុក្ខប្បត្តា ច និទ្ទុក្ខា ភយប្បត្តា ច និព្ភយា
សោកប្បត្តា ច និស្សោកា ហោន្តុ សព្វេបិ បាណិនោ

សត្វទាំងឡាយទាំងពួងដែលមានសេចក្តីទុក្ខ សូមឲ្យបាត់សេចក្តីទុក្ខទៅ ! ដែលមានភ័យ សូមឲ្យបាត់ភ័យទៅ ! ដែលមានសេចក្តីសោក សូមឲ្យបាត់សេចក្តីសោកទៅ !

រតនត្តយតេជេន កម្ពោជរដ្ឋវាសិនោ
វុឌ្ឍឹ វិរុឡ្ហឹ បប្បោន្តុ សន្តិភាវញ្ច ឆាញ្ញហិ

ដោយតេជៈនៃព្រះរតនត្រ័យ គឺព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ សូមឲ្យប្រជាជនទាំងឡាយអ្នកនៅក្នុងកម្ពុជរដ្ឋ បានលូតលាស់ចំរើននឹងសន្តិភាព កុំបីឃ្លាតឆ្ងាយទៅជាប្រការដទៃឡើយ ! ។

# រឿងព្រះអង្គុលិមាលត្ថេរ

ក្នុងសុត្តន្តបិដក មជ្ឈិមនិកាយ មជ្ឈិមបណ្ណាសក:

ឃុនបណ្ណាគារក្ស ប៊ូ-ប៉ូ

ក្រសួងពុទ្ធសាសនបណ្ឌិត្យជាអ្នកប្រែ (១)

---

សម័យនោះឯង ក្នុងដែនព្រះបាទបសេនទិកោសល មានចោរម្នាក់ ឈ្មោះអង្គុលិមាល ជាមនុស្សកាច មានដៃប្រឡាក់ឈាម ស្និទ្ធក្នុងការ ប្រៀតប្រៀននឹងការសម្លាប់ ឥតមានសេចក្តីអាណិតអាសូរពួកសត្វមានជីវិតឡើយ ។ ចោរនោះតែងធ្វើស្រុកនិគមជនបទឲ្យទៅជាមិនមែនស្រុកនិគមជនបទ តែងសម្លាប់ពួកមនុស្សហើយកាត់យកម្រាមដៃមកធ្វើជាកម្រងពាក់ ។ គ្រានោះ ព្រះដ៏មានព្រះភាគស្តេចចូលទៅទ្រង់បិណ្ឌបាតក្នុងក្រុងសាវត្ថីក្នុងវេលាព្រឹក លុះថ្ងៃរសៀល ព្រះអង្គស្តេចទៅកាន់ផ្លូវឆ្ពាយសំដៅទៅត្រង់ទីដែលអង្គុលិមាលចោរនៅ (តែមួយព្រះអង្គឯង) ។ ពួកអ្នកឃ្វាលគោ អ្នកឃ្វាលបសុសត្វ អ្នកភ្ជួររាស់ និងអ្នកដើរផ្លូវ បានឃើញព្រះដ៏មានបុណ្យកំពុងស្តេចទៅកាន់ផ្លូវឆ្ពាយសំដៅទៅត្រង់ទីដែលអង្គុលិមាលចោរនៅ ក៏ក្រាបទូលថា បពិត្រព្រះសមណៈ សូមព្រះអង្គកុំនិមន្តទៅតាមផ្លូវនោះឡើយ ដ្បិតផ្លូវនុ៎ះមានចោរឈ្មោះ

---

១ មិនបានប្រែតាមប្រយោគបាលីទេ ប្រែប្រួលកាត់យកសេចក្តីខ្លីដើម្បីឲ្យងាយស្តាប់ ។ ដោយអាងច្បាប់ព្រះត្រៃបិដកប្រែ ភាគទី ២៤ ។

អគ្គិលិមាល ជាមនុស្សក្រាច តែងសម្លាប់ពួកមនុស្ស ហើយកាត់យកម្រាមដៃមកធ្វើជាកម្រងពាក់ ៗ កាលបើពួកមនុស្សក្រាចទូលយ៉ាងនេះពីរបីដង ព្រះដ៏មានបុណ្យក៏ទ្រង់ស្ងៀម ទ្រង់ចេះតែស្តេចទៅ ៗ

ឯអគ្គិលិមាលចោរ បានឃើញព្រះដ៏មានបុណ្យកំពុងតែស្តេចមកអំពីចម្ងាយ ក៏គិតរិះថា យីអើ អស្ចារ្យណាស់ អើហ្ន៎ ចំឡែកណាស់ ព្រោះបុរស ១០ នាក់ក្តី ២០ នាក់ក្តី ៣០ នាក់ក្តី ៤០ នាក់ក្តី នាំគ្នាដើរជាពួក ៗ មកតាមផ្លូវនេះ ក៏បុរសទាំងនោះឯង ដល់នូវសេចក្តីវិនាសក្នុងកណ្តាប់ដៃរបស់អញ (ទាំងអស់) ចុះសមណៈនេះ តែម្នាក់ឯង ឥតមានគ្នីគ្នាសោះ ម៉េចក៏ហ៊ានដើរមក ហាក់ដូចជាមិនកោតញញើតឡើយ បើដូច្នោះ អញនឹងសម្លាប់សមណៈនេះ ឲ្យក្ស័យជីវិត ៗ គ្រានោះអគ្គិលិមាលចោរក៏ចាប់ដាវនឹងខែល សៀតធ្នូនឹងបំពង់ព្រួញដេញព្រះដ៏មានព្រះភាគជាប់តាមពីក្រោយ ៗ ព្រះដ៏មានបុណ្យ ទ្រង់សំដែងឫទ្ធិធ្វើឲ្យអគ្គិលិមាលចោរដែលរត់ពេញទំហឹងហើយ មិនឲ្យរត់តាមទាន់ព្រះអង្គដែលស្តេចតាមដំណើរប្រក្រតីបាន ៗ អគ្គិលិមាលចោរគិតថា យីអើ អស្ចារ្យណាស់ យីអើ ចំឡែកណាស់ ព្រោះកាលពីមុនៗមក អញស្ទុះដេញតាមដំរីកំពុងបោលក៏បាន ស្ទុះដេញតាមសេះកំពុងផាយក៏បាន ស្ទុះដេញតាមរថកំពុងលឿនក៏បាន ស្ទុះដេញម្រឹគកំពុងបោលក៏បាន ចំឡែកតែម្តងនេះ ហេតុអ្វី បានជាអញរត់ពេញទំហឹងហើយ

កំនៅតែមិនទាន់សមណៈនេះ ដែលដើរតាមដំណើរប្រក្រតីដូច្នេះ ។ អង្គុលិមាលចោរឈប់ឈរស្មៀម ស្រែកឃាត់ព្រះដ៏មានបុណ្យថា ឈប់សិនសមណៈ ឈប់សិនសមណៈ ។ ព្រះដ៏មានបុណ្យត្រាស់តបថា នែអង្គុលិមាល តថាគតឈប់ហើយ អ្នកឯងចូរឈប់ដែរទៅ ។

គ្រានោះ អង្គុលិមាលចោរគិតថា ពួកសមណៈជាសក្យបុត្រធ្លាប់និយាយតែពាក្យពិត ប្តេជ្ញាតែពាក្យពិត ចំឡែកតែសមណៈនេះ កំពុងដើរទេ ម្តេចឡើយកំនិយាយថា នែអង្គុលិមាល តថាគតឈប់ហើយ អ្នកចូរឈប់ដែរទៅ បើដូច្នោះ អញត្រវសួរសមណៈនេះមើល ។ លំដាប់នោះ អង្គុលិមាលចោរក៏ពោលនឹងព្រះដ៏មានព្រះភាគថា :

នែសមណៈ លោកកំពុងដើរសោះទេ ត្រឡប់ជានិយាយថា តថាគតឈប់ហើយ ថែមទាំងថាខ្ញុំអញដែលឈប់ហើយថា អ្នកឯងទេមិនទាន់ឈប់ ដូច្នេះវិញ នែសមណៈ អញសូមសួរដំណើរនុះនឹងលោក លោកដែលឈប់ហើយ តើដូចម្តេច អញដែលមិនទាន់ឈប់ តើដូចម្តេច ។ ព្រះអង្គតបថា នែអង្គុលិមាល តថាគតបានឈ្មោះថាឈប់ហើយ (នោះ) ព្រោះដាក់ចុះនូវគ្រឿងរាយដំបំពោះពួកសត្វ ទាំងអស់សព្វៗកាល ឯអ្នកឯងជាអ្នកមិនសង្រួមក្នុងពួកសត្វ ព្រោះហេតុនោះ អ្នកឯងឈ្មោះថាជាអ្នកមិនឈប់ ។ អង្គុលិមាលចោរតបថា "នែសមណៈ លោកស្វែងរកនូវគុណដ៏ធំ ជាអ្នកដែលទេវតានឹងមនុស្សតែងបូជា លោក

មកកាន់មហាវន (ដើម្បីសង្គ្រោះ) ដល់ខ្ញុំអស់កាលយូរហើយ ខ្លួនខ្ញុំនឹងប្រព្រឹត្តតាមនឹងលះបង់នូវបាបពោលចេញ ព្រោះបានស្តាប់នូវគាថារបស់ព្រះអង្គដែលប្រកបដោយធម៌” ជាដូច្នេះហើយ ក៏គ្រវែងដាវទឹងអាវុធចោលទៅក្នុងត្រពាំង ក្នុងជ្រោះ ក្នុងរណ្តៅ ហើយថ្វាយបង្គំព្រះបាទានៃព្រះសុគត ហើយសូមផ្នួសនឹងព្រះអង្គក្នុងទីនោះឯង ។ បំណែកព្រះសមុទ្ទ បានត្រាស់ហៅអង្គុលិមាលចោរនោះថា អ្នកចូរមកជាភិក្ខុចុះដូច្នេះ ។ ក្នុងគ្រានោះ ភិក្ខុភាវៈក៏កើតមានដល់អង្គុលិមាលចោរនោះ ។ ព្រះភគវន្តមុនីទ្រង់យកអង្គុលិមាលភិក្ខុជាបច្ឆាសមណៈ ស្តេចធ្វើពុទ្ធដំណើរសំដៅទៅក្រុងសាវត្ថី ព្រះអង្គទៅគង់នៅជេតវនារាមរបស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គាប់ជួនសម័យនោះ ពួកមហាជនកំពុងតែប្រជុំគ្នាទៀបទ្វារ ខាងក្នុងបុរីរបស់ព្រះបាទបសេនទិកោសល ស្រែកហៅគឹកកង់ថា បពិត្រព្រះសម្មតិទេព ក្នុងដែនរបស់ព្រះអង្គមានចោរម្នាក់ ឈ្មោះអង្គុលិមាល ជាមនុស្សកាច តែងសម្លាប់ពួកមនុស្ស ហើយកាត់យកម្រាមដៃមកធ្វើជាកម្រងពាក់ សូមព្រះសម្មតិទេពកំចាត់អង្គុលិមាលចោរនោះចេញ ។ លំដាប់នោះ ព្រះបាទបសេនទិកោសលស្តេចចេញអំពីក្រុងសាវត្ថី ដោយអស្សយាន ចំនួន ៥០០ ស្តេចចូលទៅកាន់អារាមទាំងថ្ងៃ បរយានទៅទល់ត្រឹមទីដែលឈប់យាន ហើយក៏ស្តេចចុះអំពីយាន ស្តេចទៅតែព្រះបាទទទេ ចូលសំដៅទៅរក

ព្រះដ៏មានបុណ្យ ដល់ហើយក្រាបថ្វាយបង្គំគង់ក្នុងទីដ៏សមគួរ ។ ព្រះដ៏មានបុណ្យទ្រង់ត្រាស់សួរថា បពិត្រមហារាជ ទំនងជាមហាបពិត្រខ្ញាល់នឹងព្រះបាទមគធសេនិយពិម្ពិសារ ឬខ្ញាល់នឹងស្តេចលិច្ឆវី អ្នកក្រុងវេសាលី ឬក៏ខ្ញាល់នឹងពួកស្តេច ដែលជាបច្ចាមិត្រឯទៀតឬអ្វី ។ ព្រះបាទបសេនទិកោសលក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គមិនខឹងនឹងស្តេចឯណាទេ ក្នុងដែនរបស់ខ្ញុំព្រះអង្គ មានចោរម្នាក់ឈ្មោះអង្គុលិមាល ជាមនុស្សកាចណាស់ ។ល។ ខ្ញុំព្រះអង្គនឹងកំចាត់អង្គុលិមាលចោរនោះចេញ ។ ព្រះដ៏មានបុណ្យត្រាស់ថា បពិត្រមហារាជ ចុះបើមហាបពិត្រត្រឡប់ជាឃើញ អង្គុលិមាលកោរសក់ពុកមាត់នឹងពុកចង្កា ស្លៀកដណ្តប់សំពត់កាសាយៈ ចេញចាកផ្ទះទៅកាន់ផ្នួសវិញ តើមហាបពិត្រត្រូវធ្វើអង្គុលិមាលនោះដូចម្តេចទៅ ។ ព្រះបាទបសេនទិកោសលក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គគប្បីថ្វាយបង្គំ ឬក្រោកទៅទទួល និមន្តដោយអាសនៈឬទំនុកបម្រុងនូវអង្គុលិមាលនោះ ដោយចីវរបិណ្ឌបាតសេនាសនៈ ថ្នាំរក្សារោគ និងបរិក្ខារទាំងឡាយ ឬនឹងចាត់ចែងនូវការរក្សាសេចក្តីការពារ និងការគ្រប់គ្រង ប្រកបដោយធម៌ ដល់អង្គុលិមាលនោះ ។

ចួនជាវេលានោះឯង អង្គុលិមាលភិក្ខុ កំពុងអង្គុយជិតព្រះដ៏មានបុណ្យៗលើកព្រះហស្តខាងស្តាំចង្អុលបង្ហាញ ព្រះបាទបសេនទិកោសល

ថា បពិត្រមហារាជ ខ្ញុំហ្នឹងអង្គុលិមាល ។ លំដាប់នោះព្រះបាទបសេនទិ-
កោសលក៏មានសេចក្ដីភ័យភិត តក់ស្លុត ព្រឺរោម ព្រឺស្បែកឡើងមួយ
រំពេច ។ ព្រះដ៏មានបុណ្យជ្រាបច្បាស់ថា ព្រះបាទបសេនទិកោសល
ទ្រង់ភ័យញាប់ញ័រព្រឺរោមដូច្នោះហើយ ក៏ត្រាស់ថា បពិត្រមហារាជ
សូមមហាបពិត្រកុំភ័យឡើយ ភ័យអំពីសំណាក់អង្គុលិមាលនេះ មិន
មានដល់មហាបពិត្រទេ ។ លំដាប់នោះ ព្រះបាទបសេនទិកោសល
បាត់ភ័យតក់ស្លុត ក៏ចូលទៅជិតអង្គុលិមាលភិក្ខុ ហើយមានព្រះឱង្ការសួរ
ថាបពិត្រលោកដ៏ចំរើន លោកម្ចាស់ឈ្មោះអង្គុលិមាលឬ ។ អង្គុលិមាល
ភិក្ខុថា ថ្វាយព្រះពរមហារាជ ។ – ចុះបិតាមាតាលោកម្ចាស់គោត្រអ្វី ។
– បិតាអាត្មាភាពជាគគ្គគោត្រ មាតាអាត្មាភាពជាមន្តានីគោត្រ ។
– បពិត្រលោកម្ចាស់ដ៏ចំរើន សូមលោកម្ចាស់គគ្គគោត្រ មន្តានីបុត្រ
អភិរម្យចុះ ខ្ញុំព្រះករុណានឹងទំនុកបម្រុងដោយចីវរ បិណ្ឌបាត សេនា
សន ថ្នាំរក្សាពេក នឹងបរិក្ខារទាំងឡាយ ដល់លោកម្ចាស់គគ្គគោត្រ
មន្តានីបុត្រ ។ សម័យនោះ អង្គុលិមាលភិក្ខុ ប្រព្រឹត្តនៅតែក្នុងព្រៃ
ប្រព្រឹត្តតែបិណ្ឌបាត ប្រើប្រាស់តែសំពត់បំសុកូល ប្រើប្រាស់តែ
ចីវរ ៣ ។ បានជាកាលនោះ អង្គុលិមាលភិក្ខុថ្វាយព្រះពរថា
កុំបាច់ទេមហារាជ អាត្មាភាពមានតែចីវរគ្រប់គ្រាន់ហើយ ។

លំដាប់នោះ ព្រះបាទបសេនទិកោសលក្រាបទូលព្រះដ៏មានបុណ្យថា បពិត្រព្រះអង្គដ៏ចំរើន អស្ចារ្យណាស់ ចំឡែកណាស់ ព្រោះថាព្រះអង្គអាចទូន្មានបុរសដែលគេទូន្មានមិនបាន អាចរម្ងាប់បុរសដែលគេរម្ងាប់មិនបាន អាចរំលត់ពុតត្បុតនៃបុរសដែលគេរំលត់មិនបាន បពិត្រព្រះអង្គដ៏ចំរើន ដ្បិតខ្ញុំព្រះអង្គមិនអាចនឹងទូន្មានទូវបុរសឯណា ដោយអាជ្ញាក្តី ដោយគ្រឿងសស្ត្រាវុធក្តី ព្រះដ៏មានព្រះភាគអាចទូន្មានបុរសនោះបានដោយមិនបាច់មានអាជ្ញា ដោយមិនបាច់មានគ្រឿងសស្ត្រាវុធក៏ឥឡូវនេះ ខ្ញុំព្រះអង្គសូមថ្វាយបង្គំលាទៅវិញ ព្រោះខ្ញុំព្រះអង្គមានកិច្ចការច្រើន មានការរវល់ច្រើន ។

លំដាប់នោះ អង្គុលិមាលភិក្ខុចូលទៅបិណ្ឌបាតក្នុងក្រុងសាវត្ថី នៅវេលាបុព្វណ្ហសម័យ ទៅតាមលំដាប់ច្រក បានជួបនឹងស្ត្រីម្នាក់ឈឺពោះសំរាលកូន លុះលោកឃើញហើយក៏គិតថា អើហ្ន៎ ពួកសត្វលំបាកណាស់ ។ ដល់ពេលរសៀល អង្គុលិមាលភិក្ខុចូលទៅគាល់ព្រះដ៏មានព្រះភាគក្រាបទូលពីដំណើរស្ត្រីឈឺពោះសំរាលកូននោះគ្រប់ប្រការ ។ ព្រះសាស្តាត្រាស់ថា ម្នាលអង្គុលិមាល បើដូច្នោះ ចូរអ្នកចូលទៅរកស្ត្រីនោះហើយនិយាយថា នែនាង តាំងពីអាត្មាកើតមកមិនដែលក្លែងផ្តាច់ផ្តិលជីវិតសត្វឡើយ ដោយពាក្យសច្ចៈនេះ សូមសិរីសួស្តីកើតមានដល់នាង សូមសិរីសួស្តីកើតមានដល់គភ៌ ។ អង្គុលិមាលភិក្ខុទូលថា ខ្ញុំ

ព្រះអង្គនឹងត្រូវសម្បជានមុសាវាទមិនខាន ព្រោះខ្ញុំព្រះអង្គបានកែងផ្តាច់ផ្តិលជីវិតសត្វជាច្រើនណាស់ ។ ព្រះអង្គត្រាស់ថា បើដូច្នោះ អ្នកចូរនិយាយនឹងស្ត្រីនោះថា នែនាង តាំងពីអាត្មាកើតហើយក្នុងអរិយជាតិ គឺបានជាអរិយបុគ្គល មិនដែលកែងផ្តាច់ផ្តិលជីវិតសត្វឡើយ ដោយពាក្យសច្ចៈនេះ សូមសិរីសួស្តីកើតមានដល់នាង សូមសិរីសួស្តីកើតមានដល់គភ៌ ។ អង្គុលិមាលភិក្ខុចូលទៅនិយាយនឹងស្ត្រីនោះ តាមព្រះពុទ្ធដីកា សិរីសួស្តីក៏បានកើតដល់ស្ត្រីនោះនឹងដល់គភ៌ គឺសម្រាលកូនរួចក្រាម ឥតលំបាកឡើយ ។

លំដាប់នោះ អង្គុលិមាលភិក្ខុ ជាបុគ្គលម្នាក់ឯង ដោះខ្លួនចេញពាកពួក ឥតមានសេចក្តីធ្វេសប្រហែស មានព្យាយាមដុតនូវកិលេសប្រថុយលះបង់នូវអត្តភាព មិនយូរប៉ុន្មាន លោកក៏បានសម្រេចព្រះអរហត្តផល ដល់វេលាបុព្វណ្ហសម័យ លោកនិមន្តទៅបិណ្ឌបាតក្នុងក្រុងសាវត្ថី ។ មានមនុស្សដទៃយកដុំដីខ្លះ ដំបងខ្លះ ក្រួសខ្លះ គេវែងបោលទៅលើកាយព្រះអង្គុលិមាល ៗ ត្រូវបួសបែកព្រះកេសហូរឈាម បែកបាត្រ រហែកសង្ឃាដី លោកក៏ចូលទៅគាល់ព្រះដ៏មានបុណ្យ ៗ ត្រាស់ទូន្មានថា ម្នាលព្រាហ្មណ៍ ចូរអ្នកខំអត់ទ្រាំទៅ អ្នកត្រូវនឹងឆេះក្នុងនរកជាច្រើនឆ្នាំ រាប់រយពាន់ឆ្នាំ ដោយវិបាកនៃកម្មឯណា អ្នកបានទទួលផលវិបាកនៃកម្មនោះក្នុងបច្ចុប្បន្ននេះ (តែប៉ុណ្ណោះទេ) ។

វេលានោះ អង្គុលិមាលភិក្ខុ ទៅនៅក្នុងទីរហោស្ថានពួនសម្ងំតែម្នាក់ឯង សោយនូវវិមុត្តិសុខ ទើបបន្លឺនូវឧទានក្នុងវេលានោះថា : « បុគ្គលឯណា ធ្វេសប្រហែសក្នុងកាលមុន តែដល់កាលជាខាងក្រោយមកបុគ្គលនោះមិនធ្វេសប្រហែសវិញ បុគ្គលនោះឈ្មោះថា ញុំាងលោក[១] នេះឲ្យភ្លឺច្បាស់ ដូចព្រះចន្ទផុតស្រឡះចាកពពក បាបកម្មដែលបុគ្គលឯណាធ្វើហើយ តែបុគ្គលនោះត្រឡប់ជាបិទបាំងបាន គឺមិនសោយផលកម្មវិញ ដោយសារកុសលគឺមគ្គ បុគ្គលនោះឈ្មោះថា ញុំាងលោកនេះឲ្យភ្លឺច្បាស់ដូចព្រះចន្ទផុតស្រឡះចាកពពក ភិក្ខុឯណា ជាកំឡោះនៅឡើយ ប្រកបព្យាយាមក្នុងព្រះពុទ្ធសាសនា ភិក្ខុនោះឯងឈ្មោះថា ញុំាងលោកនេះឲ្យភ្លឺច្បាស់ ដូចព្រះចន្ទផុតស្រឡះចាកពពក »

សូមពួកមនុស្សជាសត្រូវស្តាប់នូវធម្មកថារបស់ខ្ញុំ សូមពួកមនុស្សជាសត្រូវនឹងខ្ញុំ ប្រកបព្យាយាមក្នុងព្រះពុទ្ធសាសនា ពួកសប្បុរសឯណា តែងដឹកនាំមនុស្សឲ្យរៀនធម៌ សូមពួកមនុស្សជាសត្រូវនឹងខ្ញុំ សេពគប់នូវពួកសប្បុរសទាំងនោះចុះ សូមពួកមនុស្សជាសត្រូវនឹងខ្ញុំស្តាប់ធម៌ដ៏ជាទីផ្គូរផ្គងដល់ខន្តី ទាំងជាទីសរសើរនូវការមិនខឹងគឺមេត្តាតាមកាលដ៏សមគួរផង សូមពួកមនុស្សជាសត្រូវនឹងខ្ញុំ បំពេញនូវធម៌នោះផង

---

១ ពាក្យថា លោក ក្នុងទីនេះ សំដៅយកខន្ធ ធាតុ អាយតនៈរបស់ឯង ។ អដ្ឋកថា ។

មនុស្សឯណាជាសត្រូវនឹងខ្ញុំ សូមសត្រូវនោះកុំបីបៀតបៀនខ្ញុំ ទាំងកុំបៀតបៀនទូវបុគ្គលដទៃណាមួយឡើយ សូមឲ្យដល់នូវសេចក្ដីសុខគឺព្រះនិព្វាន ចូររក្សានូវមនុស្សដែលប្រកបដោយតណ្ហា នឹងមនុស្សដែលមិនមានតណ្ហា ។

ពួកអ្នកបង្ហូរទឹករមែងបង្ហូរទឹក (តាមប្រឡាយទឹក) ពួកអ្នកធ្វើកូនសររមែងពត់កូនសរ ពួកអ្នកចាំងឈើរមែងចាំងឈើ អ្នកប្រាជ្ញទាំងឡាយរមែងទូន្មានខ្លួន ។

ពួកមនុស្សខ្លះគេទូន្មានដោយដំបង ដោយកង្វេរ ដោយរំពាត់ ចំណែកខ្ញុំជាអ្នកមានប្រាជ្ញា ដែលព្រះដ៏មានបុណ្យជាតាទិបុគ្គលមិនបានយកដំបង ឬគ្រឿងសាស្ត្រាវុធ (មកទូន្មានខ្ញុំទេ) កាលដើមខ្ញុំឈ្មោះថា អហឹសកកុមារ (ជាអ្នកមិនបៀតបៀនគេ) តែជាអ្នកបៀតបៀនគេដល់មកថ្ងៃនេះ ខ្ញុំមានឈ្មោះទៀងទាត់ គឺសមតាមឈ្មោះដើមរបស់ខ្ញុំ ព្រោះខ្ញុំលែងបៀតបៀននូវអ្នកណាមួយហើយ កាលពីដើមខ្ញុំជាចោរមាននាមប្រាកដថា អង្គុលិមាល ដែលជំនន់ធំបន្សាត់ទៅ (តែឥឡូវនេះ) ខ្ញុំបានដល់នូវព្រះពុទ្ធជាទីពឹងហើយ កាលពីដើម ខ្ញុំមានដៃប្រឡាក់ឈាម មាននាមប្រាកដថា អង្គុលិមាល (តែឥឡូវនេះ) សរណគមន៍ខ្ញុំបានដល់ហើយ តណ្ហាជាគ្រឿងនាំទៅកាន់ភព ខ្ញុំបានរំលើងចោលហើយ ខ្ញុំបានធ្វើអំពើដែលគួរទៅកាន់ទុគ្គតិដូច្នោះជាច្រើន

តែកម្មវិបាក គឺមគ្គចេតនាបានមកអប់រំ (ក្នុងសន្តានខ្ញុំហើយ) ខ្ញុំជាអ្នកមិនមានបំណុលគឺកិលេស បរិភោគភោជន ពួកជនពាលឥតប្រាជ្ញាតែងប្រកបនូវសេចក្ដីប្រមាទ ឯអ្នកប្រាជ្ញតែងរក្សានូវសេចក្ដីមិនប្រមាទទុក ដូចទ្រព្យដ៏ថ្លៃថ្លា សូមអ្នកទាំងឡាយកុំប្រកបនូវសេចក្ដីប្រមាទឡើយ កុំប្រកបនូវសេចក្ដីត្រេកអរនឹងការមូលមិត្រក្នុងកាមឡើយ ព្រោះជាបុគ្គលអ្នកមិនប្រហែសធ្វេស ខំដុតបំផ្លាញ (នូវកិលេស) រមែងបានដល់នូវសេចក្ដីសុខដ៏ទូលាយ ខ្ញុំមកល្អហើយ ខ្ញុំមិនគេចចេញទេ គំនិតនេះ ខ្ញុំមិនមែនគិតខុសទេ បណ្ដាធម៌ទាំងឡាយដែលព្រះអង្គចែករលែកល្អហើយ ព្រះនិព្វានឯណា ជាគុណជាតិដ៏ប្រសើរ ខ្ញុំបានដល់នូវព្រះនិព្វាននោះហើយ ខ្ញុំមកល្អហើយ ខ្ញុំមិនគេចចេញទេ គំនិតនេះខ្ញុំមិនមែនគិតខុសទេ វិជ្ជា ៣ ប្រការខ្ញុំបានសម្រេចហើយ ពុទ្ធសាសនាខ្ញុំបានធ្វើតាមហើយ ។

អង្គុលិមាលសូត្រចប់ប៉ុណ្ណេះ ។

# ការបណ្តុះនិស្ស័យ


ព្រះមហាឧត្តមវិជ្ជា ជិលញាណោ ប៊ុង-ប៉ម

អាចារ្យសាលាបាលីរង វត្តបទុមវតី ក្រុងភ្នំពេញ រៀបរៀង

ឃុនបណ្ណានុរក្ស ប៊ូ-ប៉ូ នៅពុទ្ធសាសនបណ្ឌិត្យ អ្នកពិនិត្យ


(តមក)

---

២ — បេះពឹងខ្លួនឯង — ពាក្យប្រដៅរបស់ព្រះពុទ្ធម្ចាស់ថា: "ខ្លួនជាទីពឹងរបស់ខ្លួន មនុស្សដទៃណាម្តេចនឹងគប្បីជាទីពឹងបាន" នេះជាពាក្យសម្រាប់ដាស់តឿនឲ្យយើងបេះពឹងខ្លួនឯង ។ ពិតមែនយើងនឹងមានជីវិតរស់នៅបាន ដោយសារអាស្រ័យខ្លួនឯងជាមូលហេតុ. យើងខ្វះមាសប្រាក់ ឈ្មោះថាខ្វះច្រើន យើងខ្វះមិត្តសំឡាញ់ ឈ្មោះថាខ្វះច្រើនជាងខ្វះមាសប្រាក់ បើខ្វះការបេះពឹងខ្លួនឯង ឈ្មោះថាខ្វះទាំងអស់ ខ្វះទាល់តែទៅជាមនុស្សអនាថាគ្មានទីពឹង ។ មើលចុះដើមឈើគ្មានផ្លែ បក្សីមិនចុះទោម, ព្រៃគ្មានម្លប់ឈើ សត្វមិននៅអាស្រ័យ, ឈើគ្មានផ្កា ភមរជាតិមិនត្រូវការ, ជ្រោះគ្មានក្រសែទឹក ត្រីមិននៅ, នាយចៅហ្វាយមិនសំបូណ៌សម្បត្តិ បាវព្រាវរត់ចេញ, ប្រុសគ្មានទ្រព្យ សូម្បីនៅក្មេង ក៏ស្រីងាកចេញឆ្ងាយដែរ ។ ចូរបរិភោគអាហាររបស់លោក-អ្នក ដែលជាផលកើតឡើងដោយសារ

ញើសក្អែលរបស់ខ្លួន ព្រោះលោក-អ្នកជាមនុស្សមួយ ដែលច្បាប់ធម្មជាតិបានបញ្ជូនចូលមកក្នុងលោកនេះ ជាមួយនឹងជើងពីរដៃពីរ ដែលវែង ៗ មាំ ៗ ល្មមឈាននឹងឈោងទៅយករបស់ដែលគួរប្រាថ្នាណា ៗ បានសមតាមប្រាថ្នាគ្រប់យ៉ាង ។ "ក្នុងករណីយកិច្ចគ្រប់យ៉ាង យើងត្រូវពឹងខ្លួនឯង ច្រើនជាងពឹងនរណា ៗ ទាំងអស់" នេះជាពាក្យមង្គលសម្រាប់ឲ្យយើងនឹករឭកដល់ការបេះពឹងខ្លួនឯង ។ ជោគវាសនា មិនអាចជួយមនុស្សឲ្យសំរេចសេចក្តីប្រាថ្នាបានទេ ។ បើតាមពិត ការដែលសំរេចតាមសេចក្តីប្រាថ្នានោះ នៅត្រង់ការបេះពឹងការងាររបស់ខ្លួនឯង ។ បើមាត់របស់លោក-អ្នកស្រែកសូមជំនួយអំពីទេវតា ហើយដៃរបស់លោក-អ្នក ក៏ខំប្រកបធ្វើការងារ ដោយសេចក្តីប្រឹងប្រែងមែនទែន នោះទេវតានឹងជួយលោក-អ្នកពុំខាន ។ តែបើលោក-អ្នកបានត្រឹមតែមាត់ស្រែកអង្វរករសូមឲ្យទេវតាជួយតែម្យ៉ាង ឥតធ្វើការអ្វីសោះ ក៏ប្រហែលគ្មាននឹងការថ្លែងទុក្ខប្រាប់មនុស្សគេ ដែលនិយាយមិនបានច្បាស់លាស់ដែរ ។

ការបេះពឹងខ្លួនឯង គឺជាកូនសោមាសដែលសំរាប់ចាក់បើកទ្វារដើរទៅកាន់ជោគលាភ ។ បើលោក-អ្នកស្រឡាញ់ការពឹងខ្លួនឯង គួរស្វែងរកទីពឹងដែលល្អជាងខ្លួនក្នុងខ្លួនឯង ល្អជាងការវង្វេងទៅរកទីពឹងក្នុងខ្លួនអ្នកដទៃ ព្រោះខ្លួនឯងជាឃ្លាំងនៃការទីពឹងពុំនាក់ដ៏ប្រសើរ ។

បើលោក អ្នកអាស្រ័យខ្លួនឯងជាទីពឹងពិតមែនហើយ លោក-អ្នកក៏នឹងទៅជាឥស្សរសេរីជនពេញទី មានចិត្តក្លាហានរីករាយ មានជីវិតដ៏ថ្មីស្រឡាង ក្នុងវត្តគ្រប់ចំណែកនៃអត្តភាវៈ តែការៈដែលធ្ងន់ឲ្យស្រាលដំរះពង្រាបដងផ្លូវ ដែលជាទីធ្វើដំណើរទៅនៃជីវិតឲ្យស្អាតរាបទាបល្អ ហើយតទៅ លោក អ្នកនឹងលែងពោលកែខ្លួនដោយអាងដល់ជោគវាសនាថា "ខ្លួនជាមនុស្សមានវាសនាតិច មិនមានបុណ្យព្រេងសំណាងដូចអ្នកដទៃ មិនមាននរណាមួយឧបត្ថម្ភគាំទ្រ មិនមាននរណាជួយលើកដំកើងខ្លួនឲ្យអណ្តែត" ។ កាលជ្រាបដូច្នេះហើយ លោក-អ្នកត្រូវពឹងខ្លួនឯង តាំងចិត្តធ្វើការងារទៅតាមបំណងដែលខ្លួនប៉ុនប៉ង នឹងមិនត្រូវប្រែត្រឡប់ ឬ នៅស្ងៀមនឹងថ្កល់ឡើយ ត្រូវពឹងអាស្រ័យខ្លួនឯងធ្វើការងារដោយសេចក្តីប្រឹងប្រែងមែនទែន មិនត្រូវបណ្តោយខ្លួនឲ្យរង់ចាំតែឱកាសល្អមកដល់ នឹងមិនត្រូវកាន់យកសេចក្តីលំបាកក្នុងខណៈជាមួយគ្នាឲ្យច្រើនជាងអ្នកម្ចាស់ មិនត្រូវកាន់យកបែបយ៉ាងនៃមនុស្សដែលមាននិស្ស័យធ្លាប់ទីពឹងអ្នកដទៃ ដែលចូលចិត្តនាំយកសេចក្តីលំបាកចូលមកទុកក្នុងខ្លួនដល់ទៅ ៣ យ៉ាងគឺ សេចក្តីលំបាកដែលខ្លួនធ្លាប់ប្រសព្វមកហើយ, សេចក្តីលំបាកក្នុងបច្ចុប្បន្ន នឹងសេចក្តីលំបាកក្នុងកាលដែលនឹកឃើញថា នឹងជួបប្រទះក្នុងវេលាខាងមុខទៀត ។

ពិតមែន និស្ស័យពាំនឹងអ្នកដទៃ រមែងជាគ្រឿងចង នឹងបណ្តុះសេចក្តីអាក្រក់ឲ្យកើតផ្កាកើតផ្លែឡើងក្នុងខ្លួនឯង កាត់បង់នូវគំនិតដែល

ជាកុសល ។ មនុស្សដែលមាននិស្ស័យពំនឹងអ្នកដទៃ ឈ្មោះថាដាក់ប្រាក់ខ្លួនដោយខ្លួនឯង ។ អ្នកដាក់ប្រាក់ខ្លួនដោយខ្លួនឯង ឈ្មោះថានាំមេរោគចូលមកក្នុងខ្លួន ។ បើក្នុងខ្លួនមានពូជមេរោគគឺនិស្ស័យពំនាក់អ្នកដទៃហើយ រោគគឺភាពជាមនុស្សអនាថា ក៏កើតឡើងជាបន្ទាប់តទៅទៀត, មនុស្សកើតរោគអនាថានោះ ត្រូវឃុំគ្រងរាងកាយដោយសំពត់រហែក ហ៊ុមហចិត្តរបស់ខ្លួនដោយកម្មដ៏លាមក. អស់សេចក្តីគោរពរាប់អានគុណខ្លួនឯង ប្រាសចាកសេចក្តីស្មោះត្រង់ មានកម្លាំងទន់ខ្សោយនឹងក្តៅក្រហាយគ្រប់យ៉ាង ត្រូវដើរសូមទានគេបរិភោគខ្លះ លបលួចគេបរិភោគខ្លះ មិនចូលចិត្តធ្វើការងារឲ្យជាដុំកំភួន ជាមនុស្សទន់ទោរមិនមានឆ្អឹងទ្រនុងខ្លួន ធ្ងន់មិនយកស្រាល មិនស៊ី ចូលចិត្តធ្វើការងារដូចដង្កូវដែលរោះវត្ថុចូលទៅគ្រាន់តែដើម្បីរកអាហារបរិភោគ គឺថា បើធ្វើការអ្វីគ្រប់យ៉ាង ធ្វើដោយសារតែសេចក្តីចង់រស់បង្គាប់ឲ្យធ្វើ ដើម្បីឲ្យខ្លួនបានអាហារបរិភោគគ្រប់ថ្ងៃ និងមានកន្លែងនៅគ្រប់គ្រាន់ប៉ុណ្ណោះ ជាមនុស្សរស់នៅតែត្រឹមមាត់ត្រឹមថ្ងៃ មិនបានគិតនឹងបណ្តុះខ្លួនឲ្យជាទីពឹងរបស់ខ្លួន មិនប្រាថ្នានឹងឲ្យខ្លួនឈានទៅមុខ មិននឹកដល់សេចក្តីរុងរឿងនៃជីវិត ពិចារណាឃើញតែការងារថាជាសេចក្តីលំបាកយ៉ាងពន្លឹក គិតឃើញតែត្រង់ថាធ្វើមិនបាន ឃើញតែការអាស្រ័យពំនាក់អ្នកដទៃ បានបរិភោគបន្តិចបន្តួចលំបាកវេទនាថាជារបស់ល្អ ឈ្មោះថាធ្វើខ្លួនឲ្យជា

សត្រូវរបស់ប្រជាគម មិនខុសអ្វីអំពីសង្កើច - មូសដែលតាមពេមបរិភោគឈាមមនុស្សសត្វទេ ព្រោះក្រៅអំពីការធ្វើខ្លួនឯងឲ្យក្តៅក្រហាយហើយ គង់នៅបង្កសេចក្ដីវិនាសឲ្យដល់មនុស្សដទៃទៀត ជាមនុស្សទន្ទឹងចាំតែទទួលផលនៃការងាររបស់មនុស្សដទៃ ធ្វើខ្លួនឲ្យជាដង្កូវ ឲ្យជាមនុស្សចំណាយពួក ឲ្យជាបញ្ញើក្អែកទម្ងន់លោក ដោយការមិនដឹង ឬក្លែងបំភ្លេចនាទីរបស់ខ្លួនចេញ ។ "មកនេះ! ទៅ! ចុះ! ក្រោកឡើង! និយាយ! ស្ងៀម!)" ពាក្យអំបាលនេះ ជាពាក្យរបស់អ្នកមានទ្រព្យបង្គាប់បញ្ជាលេងនឹងមនុស្សជគាអាប់ ដែលប្រាថ្នាតែពឹងគេ ដើមមុខចូលទៅរកគេដោយចង់បានទ្រព្យចិញ្ចឹមជីវិត ។ ប្រយ័ត្នកុំឲ្យគេបង្គាប់លេងនឹងលោកអ្នកដូចេះ នាំឲ្យខូចកិត្តិយស ។

លក្ខណៈនៃការចេះពឹងខ្លួនឯងនោះ ក៏គឺការចេះជួយខ្លួនឯង ។ លោក - អ្នកចូរជួយខ្លួនឯងដោយការសិក្សា, ដោយការធ្វើការងារនឹងដោយការប្រព្រឹត្តសម្មាចារី ។ ព្រោះការសិក្សាជាអណ្ដូងកើតនៃចំណេះវិជ្ជា, ការប្រកបការងារ ជាអណ្ដូងហូរមកនៃគោលចារិកដ៏មាំមួន គឺទ្រព្យសម្បត្តិ, ការប្រព្រឹត្តសម្មាចារី ជាគ្រឿងថ្លៃលោកអ្នកឲ្យជាមនុស្សល្អ ។ ចំណេះវិជ្ជា, គោលចារិកដ៏មាំមួន និងសេចក្ដីល្អនោះ ចាត់ជាជាមតិកយ៉ាងសំខាន់ចំពោះរូប មិនដូចជាមតិកកងចំណោមមាសប្រាក់ ដែលនរណាៗ ក៏អាចទទួលបាននោះទេ ព្រោះយើងអាចប្រើ

ប្រាក់ ទិញគ្រឿងឧបភោគបរិភោគ ឬចាយវាយជួយមនុស្សដទៃឲ្យធ្វើការងារឲ្យយើងបាន តែយើងមិនអាចនឹងទិញសតិបញ្ញាចំណេះវិជ្ជា និងសេចក្ដីល្អអំពីមនុស្សដទៃ យកមកធ្វើជារបស់ខ្លួនបានឡើយ យើងនឹងទិញបានក៏ដោយសារតែការចេះជួយខ្លួនឯងម្យ៉ាងប៉ុណ្ណោះ ។ ព្រោះការចេះជួយខ្លួននោះឯង បង្រៀនយើងឲ្យចេះបរិភោគទឹក បរិភោគនំផ្អែមឆ្ងាញ់ និងអាហារប្រណីតបញ្ចង់របស់ខ្លួនឯង ឲ្យចេះប្រើគ្រឿងឧប-ភោគបរិភោគដែលជារបស់ខ្លួនឯង ឲ្យចេះសិក្សាវិជ្ជាដោយធន្ទៈឧស្សាហៈ ឲ្យចេះធ្វើការងារ បង្កើតការរកទ្រព្យសម្បត្តិ កងដីកងទឹកដោយសេចក្ដីប្រឹងប្រែងយ៉ាងម៉ឺងម៉ាត់ និងឲ្យចេះប្រព្រឹត្តកិច្ចការដែលល្អដោយប្រយ័ត្នប្រយែង ។ សរុបសេចក្ដីឲ្យខ្លីទៅគឺថា ការចេះជួយខ្លួនឯងនោះ តែងនាំមកនូវចំណេះវិជ្ជា នូវគោលចារិកដ៏មាំទាំ និងនូវភាពជាមនុស្សល្អប្រគល់ឲ្យជាសទ្ធិដល់យើង ។

ហេតុនេះ លោក-អ្នកទើបត្រូវតែជួយខ្លួនឯង ។ បើលោក-អ្នកមិនសម្ដែងសេចក្ដីអង់អាចរបស់ខ្លួន ឲ្យអ្នកដទៃឃើញប្រត្យក្សជាមុនទេ គ្មាននរណានឹងលូកដៃចូលមកជួយលោក-អ្នកឡើយ "សាំញ៉ាំស្មៅនៅល្អគ្រាន់បើជាងសាំញ៉ាំមនុស្ស" នេះជាពាក្យបុរាណ កាលបើលោក-អ្នកធ្វើអ្វីមិនសម ឬធ្វើការងារនាំឲ្យទើសទែង ក៏មុខជាត្រូវនឹងកាសិតនេះថា ជាមនុស្សស្មុគ្រស្មាញក្នុងលោក ហើយនឹងត្រូវគេបោស

ទោលចាកសង្គមពុំបាន តែកាលបើលោក-អ្នកពឹងខ្លួនឯងបាន ដោយការជួយខ្លួនឯងហើយ មនុស្សដទៃក៏ត្រេកអរ ក្នុងការជួយលោក-អ្នក ដោយមុខរីករាយ ដូចភាសិតបារាំងថា Aide-toi le ciel t'aidera "ចូរអ្នកជួយខ្លួនអ្នកទើបទេព្តាជួយអ្នក" ។

មនុស្សដែលមាននិស្ស័យពំនាក់ដទៃ ចូលចិត្តប្រព្រឹត្តខ្លួនដូចជាបញ្ញើក្អែក ប្រាថ្នាតែនៅពឹងពាក់អាស្រ័យអែបនែបនឹងមនុស្សដទៃជានិច្ច មិនព្យាយាមធ្វើខ្លួនឲ្យជាទីពឹងរបស់ខ្លួន ដែលចាត់ថាជាបច្ច័យឲ្យមនុស្សដទៃពឹងពាក់អាស្រ័យខ្លួនផងបានទេ ។ សូម្បីក្នុងខណៈដែលនៅអាស្រ័យគេ ក៏ធ្វើខ្លួនដូចជាសត្វចាំស៊ីសាច់ឈាមគេតែមួយចំណែក ។ មាតាបិតាដែលមានបុត្តធីតា បែបបញ្ញើក្អែកនឹងបែបសត្វជាច្រើនគ្នាហើយ រមែងមានតែការទ្រុឌទ្រោមធ្លាក់ទៅកាន់សេចក្តីវិនាសទើបមិនរួចឡើយ ។ កាលបើនិយាយឲ្យឆ្ងាយទូទៅដល់ប្រទេសជាតិផង ក៏គង់ឃើញថា ប្រទេសណាដែលមានតែពលរដ្ឋខ្ជិលច្រអូសទន់ខ្សោយ បណ្តោយខ្លួនឲ្យពឹងអាស្រ័យតែមនុស្សដទៃ ប្រទេសនោះនឹងត្រូវសំយុងមុខចុះទៅកាន់សេចក្តីវិនាសលិចលង់ ព្រោះពលរដ្ឋទាំងនោះជាមនុស្សចំណាយខ្លួនឯង, ចំណាយគ្រួសារ, ចំណាយប្រជុំជន រហូតដល់ចំណាយជាតិ ភូមិ, ស្រុក, ប្រទេស របស់ខ្លួនឯងផង ។

លោក-អ្នកជាបង្គោលមួយរបស់ជាតិ បើប្រាថ្នាចង់ឃើញប្រទេសជាតិចំរើនរុងរឿង ក៏ត្រូវកុំធ្វើខ្លួនឲ្យដូចជាបញ្ញើក្អែកឬសត្វ ដែល

ជំរុញចិត្តឲ្យរកសេចក្តីស្រួលសប្បាយតែចំណែកខ្លួន ដោយការពឹងពាក់អ្នកដទៃតែមួយចំណែកនោះឡើយ ។ ចូរព្យាយាមជួយខ្លួនឯង ដោយការកសាងខ្លួនឲ្យជាកោះសម្រាប់ទ្រទ្រង់ខ្លួនឯង, ដោយការសិក្សាសាងខ្លួនឲ្យជាទីពំនាក់របស់ខ្លួនឯង, ដោយការងាររឹងសាងខ្លួនឲ្យជាទីពឹងរបស់ខ្លួន ដោយការប្រព្រឹត្តសម្មាចារី ។ កាលបើលោក-អ្នកពឹងខ្លួនឯងបានហើយ សូម្បីពឹងអ្នកដទៃក៏ងាយ ប៉ុនគ្នានឹងពឹងខ្លួនឯងដែរ គឺពឹងគុណសេចក្តីល្អរបស់ខ្លួនឯង ។ ព្រោះលោក អ្នកមានគុណ គឺសេចក្តីល្អ ល្មមជាទីពឹងរបស់មនុស្សដទៃ នឹងល្មមឲ្យលោក-អ្នកពឹងពាក់អាស្រ័យមនុស្សដទៃបាន ។ មួយទៀត កាលបើលោក-អ្នកជួយខ្លួនឯងបានហើយ ក៏អាចជួយគ្រួសារ, ជួយពួកញាតិ ជួយមិត្តភក្តិ នឹងជួយជាតិបានផងក្នុងវេលាដែលត្រូវការ ។

បើចង់ឲ្យមានឥស្សរភាពពិតប្រាកដមែន ចូរមានជីវិតជាគួរកោះសម្រាប់យឹតយោងសណ្ដាងខ្លួនឯង កុំមានជីវិតសម្រាប់តែនៅអាស្រ័យនឹងកោះរបស់អ្នកដទៃឡើយ ។ ព្រោះការប្រព្រឹត្ត ដោយមិនអាស្រ័យកោះរបស់អ្នកដទៃ រមែងឲ្យផលល្អដល់ជីវិត ។ បើពឹងអ្នកដទៃ ត្រូវមានការអាស្រ័យកោះរបស់គេ ទើបបន្តជីវិតទៅបាន ហើយកាលឥតអំពីគេទៅ ខ្លួនក៏មិនអាចនឹងរស់នៅបានស្រួល ។ មនុស្សទាំងអស់គ្មាននរណាមួយសុខចិត្តស្លាប់ទេ ដូច្នេះកាលបើឃើញអ្នកណាមួយតាំង

ខ្លួនបានមាំមួនហើយ គឺនាំគ្នាចូលទៅនៅកាន់ស្រែយផង ។ សម្បីពួកទេវតា ក៏តែងប្រសិទ្ធពរ ដល់អ្នកដែលមាំមួននោះ ឲ្យមានអាយុយឺនយូរអង្វែង ព្រោះគេពឹងខ្លួនឯងបាន ហើយឲ្យអ្នកដទៃពឹងបានទៀតផង ។ លោក-អ្នកចូរនឹកជានិច្ចថា: ប្រមុខរបស់ខ្លួនយើង គឺជីវិត.ហ្នឹងឯង, មនុស្សដែលអស្រ័យគេចិញ្ចឹមជីវិត, មនុស្សខ្ជិលច្រអូស, មនុស្សស្អប់ខ្ពើមការងារ, មនុស្សមើលងាយការងារ ដើរទ្រលទ្រល, មនុស្សល្ងោកខ្លាំង ចូលចិត្តតែឆបោកលបលួចគេបរភោគ នឹងមនុស្សចូលចិត្តលេងល្បែងភ្នាល់ មនុស្សទាំងនេះឯងជាពួកដែលត្រូវបានទទួលចំណែក នៃសេចក្ដីទុក្ខយ៉ាងខ្លាំងក្លា មិនអាចនឹងតាំងខ្លួនឲ្យបានរហូតទៅអស់ ១ ជាតិទេ ។

៣– ពេះជឿខ្លួនឯង — ការជឿខ្លួនឯង ជាបុសគល់នៃករណីយកិច្ចគ្រប់យ៉ាង ។ ព្រោះថាកម្មគឺការធ្វើ ការនិយាយ នឹងការគិតដែលនឹងអាចសម្រេចជាផលបាននោះ ត្រូវមានជំនឿចំពោះខ្លួនឯងជាប្រធានាំ, មានការតាំងចិត្តធ្វើពិត ១ ជាចក្រនាំឲ្យផល, មានវីរិយ:ឧស្សាហ: ជាគុណភាព, មានសាមគ្គីជាគ្រឿងប្រកបប្រាបប្រាមគ្នូចក្រឲ្យជិតស្និទ្ធគ្នា ធ្វើដំណើរទៅបានស្រួលមិនលំបាក ។ កាលបើលោកអ្នកចាប់ធ្វើការងារណាមួយ ដោយសេចក្ដីសង្ស័យ ដោយចិត្តមិនចុះស៊ប់ព្រោះខ្វះជំនឿចំពោះខ្លួនឯងហើយ សម្បីមានដម្រេះវិជ្ជាច្រើន ក៏ធ្វើ

ការងារនោះឲ្យសម្រេចទៅពុំបាន ឬប្រសិនបើធ្វើអ្វីបាន ក៏ដោយសារតែមានអ្នកនាំផ្លូវ ឬអ្នកបង្គាប់បញ្ជា បើមិនមានអ្នកបង្ហាញផ្លូវ ឬអ្នកបង្គាប់ទេ ក៏ធ្វើការអ្វីមិនសម្រេចដែរ ។ តែកាលបើលោកអ្នកមានដម្រេះវិជ្ជាច្រើន ហើយមានជំនឿចំពោះខ្លួនឯងប្រកបផ្សំផង ព្រមទាំងចាប់ធ្វើដោយចិត្តខ្ជាប់ខ្ជួន ដោយចិត្តស្ម័គ្រស្រឡាញ់ការងារយ៉ាងពិត ៗ ផង ក៏រមែងធ្វើការងារនោះ ៗ ឲ្យបានសម្រេចផលល្អជាងអ្នកដែលមានវិជ្ជាច្រើន តែមានជំនឿចំពោះខ្លួនឯងតិចទៅទៀត ។

មែនហើយ វិជ្ជានោះជារបស់ល្អបំផុត អាចឲ្យអ្នកសិក្សាក្លាយទៅជាមនុស្សមានប្រាជ្ញាប្រីជាឈ្លាសវៃស្ទាត់ជំនាញបាន តែបើជាវិជ្ជានោះចូលទៅប្រកបទឹងការងារហើយ អាចអំណោយលទ្ធផលក្នុង ១០០ ភាគ បានត្រឹមតែ ១៥ ភាគ (១៥ %) ឯ ៨៥ ភាគទៀត (៨៥ %) នោះ នៅត្រង់លក្ខណៈជឿខ្លួនឯង ។ ដូច្នេះមនុស្សដែលមានវិជ្ជាជាន់ខ្ពស់ហើយ តែគ្មានជំនឿចំពោះខ្លួនឯង ទើបមិនចាត់ថាជាអ្នកអាចធ្វើការងារឲ្យសម្រេចបានទេ ។ មនុស្សដែលធ្វើការងារឲ្យសម្រេចបាននោះ គឺមនុស្សដែលជឿខ្លួនឯងព្រមទាំងមានវិជ្ជាផង មិនមែនជាមនុស្សសង្ស័យឬល្ងង់ខ្លៅគឺមនុស្សតាំងចិត្តធ្វើពិត ៗ មិនមែនឡេះឡោះបានតែមាត់ក្រៅ, គឺមនុស្សមានវីរិយៈ ឧស្សាហ ព្យាយាម មិនមែនមនុស្សខ្ជិលច្រអូសបានតែខាងសូមគេ, គឺមនុស្សដែលត្រេកអររួមដៃរួមចិត្ត រួមកម្លាំងគ្នាទទួលខុស

ត្រូវ មិនមែនមនុស្សរកតែគេបេះ, គឺមនុស្សដែលជួយផ្ទុកការងារលើស្មា មិនមែនមនុស្សឈរ ចុកអង្គុយមើលព្រងើយកន្តើយ ៗ

និស្ស័យជឿខ្លួនឯង ជាអាវុធសំខាន់បំផុត អាចឈ្នះឧបសគ្គ ទឹងសេចក្ដីលំបាកគោកយ៉ាកទៀយហាត់ចុះទគ្រប់បែប ធ្វើឲ្យយើងដំណើរកិច្ចការទៅបានយ៉ាងហូរហែរហូតផុតប្រាំង ៗ លោក-អ្នកចូរបណ្ដុះនិស្ស័យជឿខ្លួនឯង កំចាត់និស្ស័យរួញរា សទ្ធិះសង្ស័យទឹងអល់ឯកកន្ធុះរាចេញ ធ្វើខ្លួនឲ្យពេញជាខ្លួនរបស់ខ្លួនឯង អប់រំឲ្យមានចិត្តជាសមាធិ បេះបង្ហាត់ចិត្តឲ្យក្លាហានមុឹងមាំតក្នុងការងារ បើជាទឹងធ្វើ ក៏ត្រូវចាប់ធ្វើភ្លាម តែត្រូវបេះជឿខ្លួនឯងយ៉ាងសុភាព បណ្ដុះនិស្ស័យដែលធ្វើឲ្យអ្នកដទៃស្រឡាញ់ចូលចិត្តឲ្យមានរឿងក្នុងខ្លួន កុំរាយប៉ុកចិត្តមុឹតក្រអឺតក្រទមដោយសំគាល់ថាខ្លួនជាមនុស្សវិសេសឯកឡើយ ត្រូវគិតដល់បុគ្គលដទៃផង ៗ ចូរបណ្ដុះនិស្ស័យជឿខ្លួនឯងតាមគោលទាំងនេះ គឺ:

ក) បណ្ដុះនិស្ស័យជឿខ្លួនឯងដោយលក្ខណៈតទៅនេះ គឺ: យឹតយោង់ខ្លួនឲ្យត្រង់អង់អាច, អង្គុយឲ្យត្រង់ក្នុងកាលអង្គុយ, ឈរឲ្យត្រង់ក្នុងកាលឈរ, ប្រយ័ត្នក្នុងកាលដើរ ដាក់សីសៈឲ្យតាំងទៅទឹងជឹង ទឹងដើរយ៉ាងរហ័សរហួន មិនយឺតពេក ៗ, បណ្ដោយឲ្យរាងកាយគ្រប់ចំណែកឲ្យសញ្ចរទៅយ៉ាងស្រួល សំដែងលំនាំឲ្យគេឃើញថា លោក-អ្នកមានជំនឿចំពោះខ្លួនឯង, ព្យាយាមកែប្រែលក្ខណៈគ្រប់តែសំដីនិយាយ

និងគ្រប់តែគរិយាបថដែលសំដែងចេញមកជាគ្រឿងសំគាល់ ដល់សេចក្ដីទាបថោករបស់ខ្លួនឯងឲ្យអស់រលីងទៅ និងធ្វើខ្លួនឯងឲ្យជតាភាសី គួរជាទីគោតខ្លាច និងគួរជាទីគោរពកោតអាន ឬចាប់ចិត្តរបស់មនុស្សដទៃ ។

១) បណ្ដុះនិស្ស័យជឿខ្លួនឯង ដោយភាពជាអ្នកទៀងត្រង់ចំពោះវេលា "ការទៀងទាត់តាមពេលវេលានោះ ជាព្រះរាជករណីយកិច្ចយ៉ាងសំខាន់របស់ព្រះមហាក្សត្រិយ៍, ជានាទីរបស់មនុស្សសុភាព និងជាសេចក្ដីត្រូវការយ៉ាងក្រៃលែង របស់បុគ្គលអ្នកធ្វើកិច្ចការទូទៅ" ។ បើយើងស្រឡាញ់ជីវិតរបស់ខ្លួនពិត ត្រូវកុំឲ្យខុសវេលាណា ។ ព្រោះពេលវេលានេះឯង ប្រកបផ្សំគ្នាឡើង កើតបានជាជីវិតរបស់យើង ។ ដូច្នេះ យើងត្រូវជាមនុស្សទៀងទាត់តាមពេលវេលា កាលបើតាំងចិត្តថានឹងធ្វើការឯណា ត្រូវធ្វើការនោះឲ្យបានតាមពេលវេលា ។ សូម្បីកាលណាត់សន្យានឹងអ្នកណា ក៏ត្រូវរក្សាកំណត់សន្យានោះកុំឲ្យឃ្លៀងឃ្លាត និងត្រូវកាន់ការដឹកនាំឲ្យសន្សំមៗ កុំឲ្យតូចតាង ព្រោះវេលាមានដំឡៃជាមាសជាប្រាក់ កុំបណ្ដោយឲ្យកន្លងទៅដោយឥតប្រយោជន៍ សូម្បីត្រឹមតែ ១ វិនាទីឡើយ ។ គ្រប់ពេលដែលកន្លងទៅដោយឥតប្រយោជន៍នោះ ជាឱកាសវិថីបើកឲ្យគ្រោះកាច លបចូលមកកាន់ការងារដោយមិនដឹងខ្លួន ។ ការទៀងត្រង់ចំពោះពេលវេលានេះ ជាវិធីប្រយ័ត្នឲ្យមនុស្សចេះប្រើពេលវេលាដើម្បីធ្វើការងារគ្រប់យ៉ាង, ឲ្យលោក-អ្នក

អស់កន្ទុល់ក្នុងចិត្តថាធ្វើអ្វី ៗ មិនសម្រេច នឹងឲ្យលោកអ្នកទៅជាទីគោរពរាប់អានទុកចិត្តរបស់មនុស្សដទៃ ។

គ) បណ្តុះនិស្ស័យជឿខ្លួនឯងដោយបង្ហាត់ខ្លួនឲ្យជាមនុស្សហ្មត់ចត់ "ដើរព្រៃកុំមើលតែព្រៃឡើយ ត្រូវមើលដើមឈើផង" នេះជាភាសិតសម្រាប់ដាស់តឿនខ្លួនឲ្យទៅជាមនុស្សហ្មត់ចត់ ពោលគឺ ធ្វើកិច្ចអ្វីក៏ដោយត្រូវធ្វើឲ្យយ៉ាងហ្មត់ចត់ ត្រូវកុំសំឡឹងឃើញតែចំណែកធំ ត្រូវមើលឲ្យឃើញតាំងពីចំណែកតូចតាចឡើងទៅជាលំដាប់ ដរាបដល់ចំណែកធំ ៗ មួយទៀតកាលបើធ្វើការអ្វី ប្រូវពិចារណាការនោះឲ្យដឹងច្បាស់លាស់ពិតប្រាកដជាមុនសិនសឹមធ្វើ កុំឲ្យភ្លាត់ខុសប្រែប្រួលទៅបាន ។

ឃ) បណ្តុះនិស្ស័យជឿខ្លួនឯង ដោយការប្រព្រឹត្តសម្មាចារី គឺប្រព្រឹត្តកិរិយាជាអ្នកសុភាពរាបសារ ស្គាល់ច្បាប់ទំលាប់ ទីទាប ទីខ្ពស់ ទីខាងក្នុង ទីខាងក្រៅ មានសម្មាគារវៈ មិនរឹងរូសរឹងត្អឹង នឹងប្រព្រឹត្តខ្លួនឲ្យល្អត្រឹមត្រូវដោយកាយ វាចា ចិត្ត មិនត្រូវប្រព្រឹត្តអំពើអាក្រក់ ថោកទាបដូចជាមនុស្សពាលឃោរឃៅ ចិត្តយង់ឃ្នង់ ស្រវឹងស្រា ជក់កញ្ឆា ជក់អាភៀន លេងល្បែងភ្នាល់ផ្សេង ៗ ដែលជាមនុស្សប្រកាន់ទិដ្ឋិមានៈ ចូលចិត្តរករឿងឈ្លោះវិវាទ ដែលជាហេតុឲ្យខូចកេរ្តិ៍ឈ្មោះ នឹងឲ្យជាទីមើលងាយនៃមនុស្សទាំងពួងនោះឡើយ ។

(មានត)

ឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង

(តមក)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នកវាងវៃឆ្លាសបើបានអាន
នឹងបេះឧបាយកលបំណាន
ទាំងមានសន្ដានស្នេហាជាតិ ។

## កណ្ឌទី ១៨

តាំងពីចូឆូសម្លាប់ឡាន់ប៉ុង ហើយឡោមព័ទ្ធលីប៉ោនៅស្រុកហៃហ្វី រហូតដល់
តាំងស៊ិននឹងឡៀពីគិតគ្នានឹងសម្លាប់ចូឆូ ។

---

ចូឆូក៏បង្គាប់ឲ្យយកខ្លួនឡាន់ប៉ុងទៅកាត់ក្បាលដោតទុកនៅមុខបន្ទាយ ហើយបរពលចូលឡោមព័ទ្ធស្រុកហៃហ្វីជុំវិញ ហើយក៏ផ្ដាំពាក្យទុកថា បើមនុស្សក្នុងស្រុករត់ចេញទៅបានត្រង់គយល្បាតពួកណា យើងនឹងយកទោសនាយទ័ពនាយកង ដែលត្រូវគ្រារក្សាគយល្បាតពួកនោះដល់អស់ជីវិត ។ ឡៀពីបានឮចូឆូដាក់គំរិតឲ្យនាយទ័ពនាយកងដូច្នោះក៏លាចូឆូវិលទៅបន្ទាយ ហើយនិយាយដាក់គំរិតលើគួនអ៊ូ, តៀវហ៊ុយ ស៊ុនខៀនឲ្យប្រុងប្រយ័ត្ន កុំឲ្យលីប៉ោនឹងអ្នកស្រុកទៅមករកគ្នាបាន ។

ខណៈកាលគៀវហុយនឹងឡាន់ប៉ុងកំពុងច្បាំងគ្នានោះ ទៅគីនឹង អង្គកាយក៏រត់មកដល់ក្រុងហៃហ្វ៊ី ហើយចូលទៅប្រាប់លីប៉ោថា ខ្ញុំបាទ បានទៅដល់ក្រុងហ្លួយណាំ បានប្រាប់អួនសុតសព្វប្រការ អួនសុតថា ឲ្យលោកបញ្ជូនកូនក្រមុំទៅឲ្យមុនវិញទើបនឹងលើកទ័ពមកជួយ ដែល នឹងលើកមកមុននោះ អួនសុតថាបានឃើញចិត្តលោកម្ដងហើយ ។

លីប៉ោក៏ប្រឹក្សាថា ឥឡូវគេឯទ័ពចូចូឡោមព័ទ្ធស្រុកយើងជុំវិញដូច្នេះ ធ្វើម្ដេចយើងនឹងឲ្យនាំកូនក្រមុំចេញទៅបាន ។ ទៅគីឆ្លើយថា កាល ចូចូបានខ្លួនឡាន់ប៉ុងយកទៅ ក៏សោកស្ដាយដឹងសេចក្ដីអស់ហើយ ដែល លោកនឹងប្រើអ្នកដទៃ ឲ្យទៅជំនួសនោះកម្រណាស់ សុំឲ្យលោកលើក ទាហានដែលមានថ្វីដៃ ជូនដំណើរឲ្យនាំកូនក្រមុំទៅដល់ប្រទល់ដែន ស្រុកហ្លួយណាំទើបនឹងចេញទៅបាន ប្រសិនបើចូចូនឹងតច្បាំងប្រការ ម្ដេច នឹងបានជួយការពារឲ្យមាំមួន ។ លីប៉ោយល់ឃើញត្រូវទើប ចាត់ប្រើគៀវលៀវនឹងកោស៊ុនឲ្យលើកទាហាន ៣,០០០ នឹងរទេះតូច ១ ហើយនិយាយថា "យើងត្រូវប្រើអ្នកឲ្យឃុំនាំខ្លួនកូនក្រមុំយើងទៅឲ្យអួន-សុត យើងនឹងជូនដំណើរអ្នកចេញទៅដល់ប្រទល់ដែនស្រុកហ្លួយណាំ, ថាហើយឲ្យកូនក្រមុំតែងខ្លួនពាក់គ្រឿងយ៉ាងមាំមួនណាស់ ។ លុះដល់ ពេលយាម ២ យប់ លីប៉ោក៏យកព្រែពណ៌ ៣ ផាប់ចងរុំខ្លួនកូនក្រមុំ ណែន ហើយស្ពាយពីក្រោយខ្នងឡើងជិះសេះកាន់ទ្ធួន នាំកោស៊ុននឹង គៀវលៀវលើកទាហាន ៣,០០០ លបចេញទៅផុតពីស្រុកហៃហ្វ៊ី" ។

ឯទាហានចូឆូដែលឡោមព័ទ្ធស្រុកនោះ មិនបានសង្កេតត្រួតត្រា ជាមាំមួន ក៏បណ្ដោយឲ្យលីប៉ោលបចេញទៅបាន ៗ លុះលីប៉ោទៅ ដល់ព្រំដែនស្រុកហ្លួយណាំទទួលគួនអ៊ូ, តៀវហ៊ុយលើកទាហានចេញ ទៅយាមល្បាតក្រៅបន្ទាយ ឃើញលីប៉ោនឹងទាហានលើកទៅដល់ តៀវហ៊ុយស្រែកថាអាលីប៉ោអាឯងលបរត់ទៅណា? ៗ លីប៉ោឃើញគួនអ៊ូ, តៀវហ៊ុយស្ទាក់ទទឹងពីមុខក៏ញាក់សេះនឹងស្ទុះទំលាយ ទទួលឡៅពីក៏ លើកទាហានតាមមកទាន់លីប៉ោពីក្រោយ លីប៉ោភ័យណាស់ខ្លាចកូន ក្រមុំនឹងអន្តរាយ ក៏បរពារទំលាយកងទ័ពចូឆូត្រឡប់ចូលទៅក្នុងស្រុក ហៃហ្វីវិញបាន ៗ ឡៅពី, គួនអ៊ូ, តៀវហ៊ុយក៏លើកទាហានតាមមក ទៀត ឡោមព័ទ្ធស្រុកនោះពីទិសខាងលិច ៗ

លីប៉ោទាល់គំនិតមិនដឹងគិតយ៉ាងម្ដេច ក៏ចេះតែផឹកស្រាព្រឹកល្ងាច មិនឈប់ឈរពេលណាសោះ ចូឆូក៏ឡោមព័ទ្ធស្រុកហៃហ្វីទុកដល់ ៣ ខែ ៗ លីប៉ោក៏មិនបានចេញតប្រាំងសោះ ចូឆូនឹងលើកទ័ពវាយទំលាយ ឃើញថាលីប៉ោត្រួតត្រារក្សាសេនបន្ទាយមាំមួនណាស់ ៗ ទទួល មានបំរើសេះនាំសេចក្ដីចូលទៅជំរាបចូឆូថា តៀវអេងចៅហ្វាយស្រុក ហោឡាយដឹងថា មហាឧបរាជលើកទ័ពមកឡោមព័ទ្ធស្រុកហៃហ្វី តៀវអេងក៏លើកទាហាននឹងមកជួយលីប៉ោ អៀវស៊ុំនាយទាហានមិន យល់ព្រមលបសម្លាប់តៀវអេងស្លាប់ ហើយកាត់ក្បាលនឹងនាំមកជូន

មហាឧបរាជ, លុះមកដល់ពាក់កណ្តាលផ្លូវ អ៊ុយក ជាមនុស្សស្និទ្ធរបស់គៀវអេងតាមមកទាន់សម្លាប់អៀវស៊ុវបាន ហើយនាំក្បាលគៀវអេងវិលទៅស្រុកវិញ ។

ប៉ូចូបានឮដូច្នោះ ក៏ប្រើស៊ូហ៊ួនលើកទាហានទៅសម្លាប់អ៊ុយកបានហើយ ប្រជុំនាយទ័ពនាយកងទាំងពួងមកប្រាប់ថា ឥឡូវគៀវអេងស្លាប់ទៅហើយ សត្រូវរបស់យើងខាងទិសឯជើងនៅបារម្ភតែគងតែអ៊ួនសៀវ ចំណែកទិសឯលិច តែគងតែឡៅពៀវនិងគៀវស៊ុវមានកំឡាំងខ្លាំងពូកែឡើង យើងនឹងទុកចិត្តមិនបាន ឥឡូវយើងមកឡោមព័ទ្ធក្រុងហៃហ៊ូទុកយូរហើយ ទាហានទាំងឡាយក៏មានតែសេចក្តីនឿយលំបាក យើងនឹងត្រឡប់ទៅស្រុកហ៊ូតោវិញ ដើម្បីនឹងបំរុងប្រុងប្រៀបរៀបចំសន្សំសេនាទាហានឲ្យមានច្រើនឡើងទៀត ទុកបង្ការស្រុកយើងឯនាយផង តើអ្នកទាំងឡាយនឹងយល់ឃើញដូចម្តេច? ។

ស៊ុនហុកឆ្លើយថា យើងធ្វើការគ្រានេះលីប៉ោក៏ថ្វាះការនឹងយើងជាច្រើនគ្រាហើយ ជិតនឹងចាល់បែកយកខ្លួនមិនរួច ដែលនឹងលើកទ័ពត្រឡប់ទៅវិញនោះ ខ្ញុំបាទយល់ឃើញថា លីប៉ោគង់នឹងមានកម្លាំងឡើងវិញ បើយើងនឹងវិលមកធ្វើការទៀតក៏លំបាកនឹងយកជ័យជំនះណាស់ ។ គុយកៃឆ្លើយថា មហាឧបរាជកុំវិតក្កព្រួយឡើយ ស្រុកហៃហ៊ូនេះជាមុខងាររបស់ខ្ញុំបាទនឹងគិតកលឧបាយវាយបំបែកបាន ។

ចចកសួរថា អ្នកនឹងគិតធ្វើប្រការម្ដេច? ។ គុយកៃឆ្លើយថា ឥឡូវនេះជាទេសកាលទឹកជំនន់ជន់ឡើងលិចគ្រប់អន្លើ ហើយហូរចុះមកក្បែរស្រែកវៃហហ៊ី ខាងទិសឯលិចសុំឲ្យលោកវរៈគិតចាត់ទាហានទប់ទឹកស្ទឹងខាងត្បូងដែលមានដងស្ទឹងហូរខាងលិចស្រុកនោះឲ្យជាប់ កុំឲ្យទឹកហូរចុះទៅបានបើមានទំនប់ដូច្នេះហើយ គង់តែទឹកនឹងហូរចូលមកក្នុងស្រុកវៃហហ៊ីលិចទាំងអស់ លីប៉ោក៏ប្ដោះការរបស់យើងជាប្រាកដ ។

ចចកបានស្ដាប់ឃើញត្រូវណាស់ ក៏ឲ្យប្រមូលទាហានចុះទៅលើកទំនប់ទប់ស្ទឹង ហើយឲ្យលើកទំនប់ទប់ព័ទ្ធជុំវិញស្រុកហូតឡើងមកបើកប្រឡាយ ១ ឲ្យហូរចូលទៅក្នុងស្រុកវៃហហ៊ី លុះមានភ្លៀងធំធ្លាក់មកទឹកនោះក៏ហូរចុះពីលើភ្នំតាមពោះស្ទឹងចុះទៅទើរលើទំនប់ ត្រឡប់ហូរចូលទៅក្នុងស្រុកវៃហហ៊ីលិចអស់ផ្ទះសំបែង ។ អ្នកស្រុកក្នុងស្រុកនោះក៏ផ្អើលជ្រួលច្របល់ខ្លាំងណាស់ បណ្ដាមនុស្សម្នាក៏នាំយកសេចក្ដីទៅជំរាបលីប៉ោៗ ក៏ថា "យើងនឹងអាល់ខ្លាចទឹកនោះធ្វើអ្វី សេះសឹករបស់យើងមានកំឡាំងច្រើនណាស់ បោលធ្លងទឹកដូចជាបោលលើគោកដូចគ្នា" ហើយលីប៉ោក៏មិនមានយកចិត្តទុកដាក់ បេះតែផឹកស៊ីសប្បាយពល់វេលា ៗ ខណៈនោះ លីប៉ោក៏ជាតាពសីថយចុះ ថ្ងៃមួយភរិយាយកកញ្ចក់មកឲ្យលីប៉ោឆ្លុះមើលមុខ ។ លីប៉ោឃើញទឹកមុខខ្លួនសៅហ្មងក៏គិតថា "ដោយហេតុផឹកស្រាច្រើន ស្រានេះរមែងជាទោសច្រើន

ណាស់ ទោះអ្នកឯណារូបស្អាតល្អដូចម្ដេចក៏គង់សៅហ្មងព្រោះស្រា ។ លីប៉ោគិតឃើញដូច្នោះ ក៏ចេញទៅប្រកាសហាមសេនាទាហានទាំងពួង ថា ពីថ្ងៃនេះតទៅបើនរណាសេពសុរានឹងយកទោសកាត់ក្បាលចេញ ។

ខណៈនោះ មនុស្សដែលថែរក្សាសេះលីប៉ោ គិតលួចយកសេះ ១៥ ទៅឲ្យឡេវពី ។ ហៅសេងជានាយត្រួតដឹងការទាន់ ក៏តាមទៅចាប់ខ្លួនមនុស្សទាំងសេះនោះទៅសម្លាប់បង់ ។ នាយទ័ពនាយកងទាំងពួងដឹងដូច្នោះ ក៏បបួលគ្នាទៅសួរហៅសេងៗ គិតចង់លៀងស្រាបណ្ដាទាហានទាំងពួង តែខ្លាចអាជ្ញាលីប៉ោ ក៏ចូលទៅដំរាបលីប៉ោថា មានអាចោរកំណាចលួចនាំសេះចេញទៅឲ្យឡេវពី ខ្ញុំបាទតាមទៅទាន់សម្លាប់អស់ទៅហើយ ពីព្រោះបុណ្យរបស់លោកមិនដែលខូចរបស់នឹងសឹកសត្រូវ ឥឡូវនាយទ័ពនាយកងទាំងពួងមកសួរខ្ញុំបាទជាច្រើន ខ្ញុំបាទចង់សុំច្បាប់លោកលៀងស្រា តើលោកនឹងប្រោសមេត្តាបានឬទេ? ។

លីប៉ោខឹងប្រឡោកឡើងថា "យើងបានហាមឃាត់ថា ស្រានេះជាទោសនឹងនាំឲ្យខូចផលប្រយោជន៍ទាំងពួង បើនរណាផឹកស្រា យើងនឹងកាត់ក្បាលចេញ ហេតុម្ដេចខ្លួនមកបរចាសុំលៀងស្រាដូច្នេះទៀត ចង់ឲ្យខូចអាជ្ញារបស់យើងឬ?" ថាហើយក៏បង្គាប់ទាហានឲ្យចាប់ខ្លួនហៅសេងនឹងយកទៅសម្លាប់ ។

ស៊ុងហៀននឹងង៉ុយសុក ក៏ចូលទៅអង្វរសុំទោសហៅសេង ។ លីប៉ោថា "ហៅសេងធ្វើខុស ទោសត្រូវប្រហារជីវិតហើយ តែយើង

យល់ដល់អ្នក ព្រមលើកទោសឲ្យរួចជីវិតម្ដងចុះ" ហើយឲ្យទាហានយកខ្លួនហៅសេងទៅវាយដោយរំពាត់ ៥០ ខ្នាប់ ។ ទាហានទាំងពួងឃើញដូច្នោះក៏គួបចិត្តពន់ពេក ។ ស៊ីងហៀនទីងនុយសុកក៏នាំគ្នាទៅសួរហៅសេងដល់ផ្ទះ ហៅសេងក៏ចេញទៅទទួលហើយនាំឡើងទៅអង្គុយនិយាយថា "កាលពីម្សិលមិញបើកុំតែអ្នកទាំងពីរទៅជួយខ្ញុំហើយ ខ្ញុំក៏មិនបានរស់ឃើញមុខអ្នកឡើយ" និយាយហើយហៅសេងអង្គុយយំ ។

ស៊ីងហៀនថា សព្វថ្ងៃនេះលីប៉ោប្រែកិរិយាខុសពីដើមប្លែកណាស់ ព្រោះមិនយកចិត្តសេនាទាហាន ជឿស្ដាប់តែពាក្យករិយា ទាល់តែបួចលើកទ័ពឡោមព័ទ្ធស្រុកទុកជុំវិញ ហើយទប់ទឹកឲ្យឡើងលិចក្នុងស្រុកទាំងអស់ ដូច្នេះហើយ លីប៉ោក៏នៅព្រងើយកន្តើយមិនយកចិត្តយើង, យើងទាំងឡាយដូចជាមនុស្សមានជម្ងឺឈឺធ្ងន់ មិនអាចដឹងថាថ្ងៃណាទីងស្លាប់ ហេតុដូច្នេះយើងត្រូវតែលះបង់ចោលលីប៉ោ គិតរត់ចេញឲ្យតែរួចអាយុជីវិតចុះ ។

នុយសុកថា បើយើងទីងរត់ចេញៈទៅទទេដូចមិនមែនជាជាតិទាហាន គួរតែយើងព្រមគ្នាចាប់ខ្លួនលីប៉ោបញ្ជូនទៅឲ្យបួច ដើម្បីយកគុណគាប់ប្រសើរជាជាង ។ ហៅសេងថា លីប៉ោនេះមានកម្លាំងខ្លាំងពូកែណាស់ មានជំនិះគឺសេះសិកថៅក៏ចំណាប់ បើយើងទីងគិតចាប់លីប៉ោគួរតែលួចយកសេះសិកថៅទៅឲ្យបួចសិន ។ ស៊ីងហៀនទីងនុយ-

សុកក៏យល់ព្រមគ្នា លាហៅសេនត្រឡប់ទៅផ្ទះ លុះដល់ពេលយប់ហៅសេនក៏ចូលទៅលួចយកសេះសិកថៅមកបាន ចេញទៅរកបូច្ចតាមផ្លូវទ្វារទិសឯកើត ហើយហៅសេនក៏នាំសេះនោះទៅជូនបូច្ច ជំរាបថាខ្ញុំបាទនឹងនុយសុក-ស៊ីងហៀន គិតគ្នានឹងចាប់ខ្លួនលីប៉ោមកជូនមហាឧបរាជ ៗ បូច្ចបានស្តាប់ក៏មានចិត្តត្រេកអរណាស់ ទើបសរសេរសេចក្តីចងនៅចុងព្រួញបាញ់ផ្ញើទៅក្នុងស្រុកហៃហ្វី សេចក្តីថា "ឥឡូវលីប៉ោអស់អំណាចដោយជតាពសីចុះហើយ ឧបមាដូចជាខ្លានៅក្នុងអណ្តូងបើប្រសិនអ្នកឯណាចាប់ខ្លួនលីប៉ោនាំទៅឲ្យយើងបាន យើងនឹងឲ្យបំណាច់ផ្ទាន់តាំងជានាហ៊ឺនធំ" ៗ លុះពេលព្រឹកឡើងបូច្ចក៏បរពលទំលាយបន្ទាយចូលទៅក្នុងស្រុក ទាហានដែលរក្សានាទីសែនបន្ទាយ ក៏តតាំងច្បាំងកាប់សម្លាប់គ្នាស្លាប់ជាច្រើន ៗ

លីប៉ោឮសំឡេងគឹកកងក៏ភ័យតក់ស្លុត ហៅទាហានឲ្យយកសេះសិកថៅ ទាហានដែលរក្សាសេះនោះជំរាបថា ហៅសេនលួចយកសេះនោះនាំទៅឲ្យបូច្ចតាំងពីយប់មិញទៅហើយ ៗ លីប៉ោក៏ចាប់យកខ្លួនស្ទុះឡើងទៅលើសែនបន្ទាយឃើញស៊ីងហៀន, នុយសុក ក៏សួរថា "ហេតុម្តេចខ្លួនឯងប្រែចិត្តទៅចូលនឹងគាហៅសេន លួចយកសេះអញទៅ បើកាលណាអញធ្វើការនេះសម្រេច អញនឹងកាត់ក្បាលឯងទាំង ២ នាក់ឲ្យបាន" ថាហើយលីប៉ោក៏បង្ខំដេញទាហានឲ្យចេញទៅតច្បាំងនឹងកងទ័ពបូច្ច តាំង

ពីព្រឹកទាល់ដល់ថ្ងៃត្រង់ ទាហានបូឆូក៏ថយក្រោយទៅវិញ លីប៉ោក៏វិលមកអង្គុយលើកៅអីនៅប្របទ្វារស្រុកខាងក្នុង ហើយយកខ្លួនផ្អែកនឹងកំពែងក៏ឆ្ងួសលក់ទៅ ៗ ស៊ុងហៀននឹងង៉ុយសុកឃើញបានការដូច្នោះ ក៏ធ្វើបដូចជាចូលទៅប្រឹក្សាការពារការ ហើយបណ្ដេញទាហានដែលនៅរក្សាខ្លួនលីប៉ោនោះឲ្យថយចេញ ង៉ុយសុកក៏កន្ត្រាក់យកខ្លួនទៅបោះចោលឆ្ងាយពីលីប៉ោ ហើយស៊ុងហៀននឹងង៉ុយសុកស្រុះព្រមគ្នា ចូលទៅយកខ្សែចងលីប៉ោៗ ភ័យភ្ញាក់ឡើងស្រែកឲ្យទាហានជួយ ទាហានទាំងអស់នោះក៏គ្មាននរណាម្នាក់នឹងចូលទៅជួយសោះ លុះចងលីប៉ោជាប់ហើយ ង៉ុយសុកក៏បើកទ្វារស្រុកស្រែកប្រាប់ប្រកាសទាហានបូឆូថា យើងចាប់ចងខ្ជាប់ហើយ ឲ្យប្រញាប់ចូលមកយកខ្លួនទៅចុះ ៗ

វ៉ៃហ៊្វីអៀនឮដូច្នោះ ក៏បំផាយសេះចូលទៅដល់ទ្វារស្រុកតែគិតសង្ស័យថា លីប៉ោនឹងធ្វើកលឧបាយដូចម្ដេចទេដឹង តែឆ្ងល់ហេតុម្ដេចក៏មិនឃើញមានសេះ ៗ ទទួលង៉ុយសុកយកខ្លួនរបស់លីប៉ោចោលចេញទៅជាសំគាល់ វ៉ៃហ៊្វូអៀននឹងទាហានទាំងពួងក៏អស់សង្ស័យ ស្រុះស្រចូលទៅក្នុងស្រុកវ៉ៃហ៊្វីបាន ៗ ឯកោស៊ុននឹងកៀវលៀវដែលរក្សាត្រួតត្រាយាមល្បាតទ្វារទិសខាងលិចដឹងថា ស៊ុងហៀននឹងង៉ុយសុកប្រទូសរ៉ាយលីប៉ោ ក៏ចុះពីលើនាទីសែនបន្ទាយទៅជួយលីប៉ោ ៗ ទទួលទាហានបូឆូទំលាយបន្ទាយទ្វារស្រុកចូលមកបាន ក៏ចាប់ខ្លួនកោស៊ុននឹង

តៀវលៀវបានទៀត ។ គាត់កុងឃើញទាហានចូចូហែកចំលាយចូលទៅក្នុងស្រុកបាន ក៏ឡើងសេះបំផាយចេញតាមទ្វារស្រុកទៅទិសឯជើង ជួបប្រទះនឹងស៊ីឡ្យុង ។ លើកទាហានព័ទ្ធចាប់ខ្លួនគាត់កុងបានទៀត ។ ចូចូក៏លើកទ័ពចូលទៅតាំងនៅក្នុងស្រុកហែហ្វី ហើយចាត់ទាហានទៅរំលើងរលាយទំនប់ដែលទប់ទឹកនោះចេញ ទឹកក៏ហូរស្រុកអស់ទៅ ហើយចូចូក៏ប្រាប់ប្រាមអស់បណ្ដារាស្ដ្រ ដែលនៅក្នុងស្រុកនោះឲ្យនៅជាសុខក្សេមក្សាន្តតាមប្រក្រតី ។

ចូចូក៏នាំទ្យាពពីឡើងទៅអន្ទុយលើសែនឈ្មោះបេកប៉ុនឡៅ គួនអ៊ូ, តៀវហ៊ុយក៏ឡើងទៅជាមួយ ចូចូក៏នាំខ្លួនលីប៉ោឡើងទៅ ។ លីប៉ោក្រឡេកឃើញទាហានទាំងពួង ព្រួតគ្នាចូលចាប់ចងខ្លួនខ្ជាប់រឹតរួតស្ទើរតែនឹងស្លាប់ដូច្នោះក៏ស្រែកថា មហាឧបរាជសូមករុណាមេត្តាខ្ញុំបាទផង ។ ចូចូថា ធម្មតាខ្លាដែលជាប់ចំណងយ៉ាងមាំមួនហើយគេមិនដែលស្រាយលែងទេ ។ លីប៉ោឮដូច្នោះក៏ទាល់គំនិត ក្រឡេកទៅឃើញហៅសេង, នឹងស៊ុងហៀន, ង៉ុយសុក ឈរក្បែរខ្លួន លីប៉ោក៏ស្ដីថា អញបានចិញ្ចឹមរក្សាជួយទំនុកបំរុងខ្លួនឯងរាល់គ្នាជាយូរមកហើយ ហេតុម្ដេចខ្លួនមកគិតទុយ៉ិសនឹងអញដល់ទីនេះ ។ ស៊ុងហៀនថា យើងធ្វើដូច្នេះ ព្រោះអ្នកឯងមិនជឿស្ដាប់ពាក្យយើងសោះ អ្នកឯងជឿស្ដាប់រាប់អានតែពាក្យភរិយា ហើយត្រឡប់មករករឿងធ្វើទោសយើងវិញ ហេតុម្ដេចក៏ថាយើងគិតទុយ៉ិសខ្លួន ។ លីប៉ោឮដូច្នោះក៏ទុញទាល់មិនដឹងឆ្លើយថាប្រការម្ដេច ។

ឯទាហានដែលចាប់ខ្លួនគោស៊ីនបាន ក៏ចងនាំទៅជូនបុច្ចៗ សួរថា អ្នកឯងមានការនិយាយនឹងយើងឬទេ? ។ គោស៊ីនមិនឆ្លើយ បុច្ចខឹងណាស់ ប្រើទាហានឲ្យនាំខ្លួនគោស៊ីនយកទៅប្រហារជីវិត ។ ក្រោយនោះ ស៊ុឡែងក៏ឃុំនាំខ្លួនតាន់កុងទាំងចំណងឡើងទៅជូនបុច្ចទៀត ។ បុច្ចសួរថា តាំងពីអ្នកឯងឃ្លាតចាកយើងមក បានសេចក្តីសុខសប្បាយជាទេឬ? ។ តាន់កុងឮដូច្នោះក៏សំគាល់ថា បុច្ចនិយាយឡកឲ្យខ្លួនក៏ខឹងខឹងណាស់ឆ្លើយថាអ្នកឯងជាមនុស្សអាក្រក់ណាស់ មិនមានសេចក្តីសត្យពិតត្រង់ មានតែឆបោកមនុស្សឲ្យវង្វេងដោយកលឧបាយ បានជាយើងរត់ចោលតាំងពីនោះមក ។ បុច្ចឆ្លើយថា យើងជាមនុស្សអាក្រក់ហើយ បានជាអ្នកឯងរត់ចេញពីយើងទៅ ហេតុម្តេចមិនទៅនៅនឹងមនុស្សល្អ ក៏បានជាមកនៅនឹងលីប៉ោជាមនុស្សអាក្រក់ទៀត? ។ តាន់កុងឆ្លើយថា លីប៉ោជាមនុស្សគ្មានដំរេះប្រាជ្ញាមិនចេះគិតការអ្វីក៏មែន តែមិនបានជាមនុស្សក្បត់កុហកដូចខ្លួន បានជាយើងចូលមកនៅធ្វើការផង ។ បុច្ចថា លីប៉ោជាមនុស្សគ្មានដំរេះប្រាជ្ញាសោះ ខ្លួនអ្នកឯងជាអ្នកមានដំរេះប្រាជ្ញា ហេតុម្តេចក៏បណ្តោយឲ្យលីប៉ោធ្វើការដូច្នេះ? ។

តាន់កុងស្តាប់ហើយងាកទៅនិយាយនឹងលីប៉ោថា ព្រោះតែខ្លួនមិនចេះស្តាប់យើងរំលឹកសោះ បានជាធ្វើការយ៉ាងនេះ បើជាស្តាប់ពាក្យយើងខ្លះ កាលណាឡើយនឹងគាប់យសខ្មាសទាហានទាំងពួងដូច្នេះ ។

បុប្ផាគាត់កុងនិយាយដូច្នោះក៏ថា លោកប៉ាមិនស្តាប់ពាក្យខ្ញុំបានជាថ្ងោះការ ឥឡូវខ្ញុំមានប្រាជ្ញានឹងគិតដូចម្តេច? ។ គាត់កុងខឹងណាស់ស្រែកគំហកថា ខ្ញុំអញគ្រានេះដល់អាយុជីវិតនឹងស្លាប់ហើយ ឯងមិនត្រូវមកដេញដោលសួរយកការធ្វើអ្វីទៀតទេ ។ បុប្ផាធ្វើជាមិនខឹងសួរថា ដែលខ្ញុំនិយាយនេះត្រូវហើយ តែថាមាតានឹងភរិយាបុត្ររបស់ខ្ញុំ ៗ នឹងគិតប្រការម្តេច? ។ គាត់កុងបានស្តាប់ក៏គិតអាល័យដល់មាតានឹងភរិយាបុត្រពន់ប្រមាណ ឆ្លើយតបទៅបុប្ផាវិញថា ធម្មតាជាតិសេនាទាហាននឹងប្រាជ្ញាតាំងខ្លួនជាធំ ពោះបើនឹងចាប់សឹកសត្រូវបាន គេក៏មិនដែលមានធ្វើអន្តរាយដល់មាតាបិតាភរិយាបុត្រសត្រូវនោះទេ គេធ្វើអន្តរាយចំពោះតែរូបអ្នកដែលប្រព្រឹត្តខុសនោះ ដូចខ្ញុំឃើញក៏មានទោសដល់អាយុជីវិតហើយ ឃើញមិនមានស្តាយរូបកាយនេះទេ តែមាតានឹងភរិយាបុត្ររបស់ឃើញ ៗ សូមផ្ញើនឹងមហាឧបកជ ៗ ត្រូវមានសេចក្តីករុណាចិញ្ចឹមរក្សាផងចុះ ។ បុប្ផាក៏នឹកលើកដល់គុណូបការគាត់កុងដែលបានជួយសង្គ្រោះដោះទុក្ខមកពីខាងដើម ប្រាជ្ញានឹងចិញ្ចឹមរក្សាគាត់កុងទុក មិនទាន់នឹងថាប្រការម្តេច គាត់កុងក៏ស្ទុះលោតចុះពីលើសេះ ដើម្បីនឹងឲ្យទាហានសម្លាប់ខ្លួនចេញ ។ បុប្ផាឃើញដូច្នោះក៏ឲ្យទាហានចាប់ខ្លួនគាត់កុងទុក គាត់កុងមិនព្រមស្តាប់ បុប្ផាក៏មានចិត្តអាណិតអាណាថដើរយំតាក្រោយទៅហើយក៏និយាយនឹងគាត់កុងថា បើអ្នកមិន

ចូលចិត្តនៅជាមួយនឹងយើងក៏វាហើទៅចុះ តែមាតានឹងភរិយាបុត្ររបស់អ្នក យើងទទួលពិក័ក្ដិរក្សា អ្នកកុំបីមានវិតក្កទុក្ខក្ដៅផ្សាឡើយ ៗ ឯគាត់កុងដើរទៅដល់ក្រៅកំពែង ក៏សំដែងអាការឲ្យទាហានប្រហារជីវិតស្លាប់ក្នុងទីនោះ ៗ ចូឆូក៏ប្រើទាហានឲ្យរៀបចំសពគាត់កុង នាំយកទៅបញ្ចុះតាមប្រវេណី ហើយឲ្យបំរើឃុំនាំយកខ្លួនមាតា នឹងភរិយាបុត្រគាត់កុងចូលទៅរក្សាទុកក្នុងក្រុងហ៊ូតោ ហាមប្រាមមិនឲ្យនរណាទៅបៀតបៀនឲ្យបានសេចក្ដីលំបាកឡើយ ៗ

ឯលីប៉ូនៅលើសែនបន្ទាយនិយាយនឹងឡៀវពីថា មហាឧបរាជកប់អានស្រឡាញ់អ្នកជាប្រាកដ គ្រានេះខ្លួនខ្ញុំពេញជាមនុស្សទោសមានទោសដល់ស្លាប់ហើយ អ្នកប្រជួយរិះគិតយកអាយុជីវិតខ្ញុំផងចុះ គុណូបការៈរបស់អ្នកនឹងមានលើខ្លួនខ្ញុំតទៅ ៗ ឡៀវពីបានឮដូច្នេះក៏នៅស្ងៀមគ្រាន់តែញាក់មុខ ៗ ទទួលចូឆូឡើងទៅលើសែនវិញ លីប៉ូក៏និយាយថា សព្វថ្ងៃមហាឧបរាជគិតការធំ បារម្ភតែខ្លួនខ្ញុំបាទមួយថា ជាមនុស្សប្រមូងប្រមះ ឥឡូវចាប់ខ្លួនខ្ញុំបាទបានហើយ ខ្ញុំបាទក៏សុំអាយុជីវិតទុកធ្វើការតបស្នងសងគុណលោកតទៅ ព្រោះអំណើះទៅមុខខ្ញុំបាទយល់ថា រាជសម្បត្តិគង់នឹងជាកម្មសិទ្ធិរបស់លោក ៗ ចូឆូបានស្ដាប់ដូច្នេះទើបសួរឡៀវពីថា ដែលលីប៉ូថាដូច្នេះ អ្នកនឹងយល់ឃើញប្រការដូចម្ដេច? ៗ

(មានត)

# ណលៈ និង ទមយន្តី

រឿងព្រេងប្រទេសឥណ្ឌា

## អ្នកស្រីស្រិង-សារិយ៉ាន់ ក្រុមពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

ប្រែពីភាសាបារាំងមកជាភាសាខ្មែរ

(តមក)

---

### វគ្គទី ៤

ព្រះនាងទមយន្តីទ្រង់ស្តេចចេញមកក្រសាលឧទ្យាន ដោយមានស្រីស្នំហែតាមក្រោយត្រសង ។ នៅក្នុងឧទ្យាននោះមានស្រះមួយដែលសម្បូណ៌ទៅដោយផ្កាឈូកពេញពាស ។ ព្រះនាងចង់ចុះស្រង់លេងក្នុងគង្គា ។ នៅពេលដែលព្រះនាងកំពុងតែហែលលេងជាសុខសាន្ត ស្រាប់តែមានក្ងានព្រៃមួយចុះបណ្តែតខ្លួនលើផែនទឹកដែលរំជួយដោយរលក ។ ព្រះនាងទមយន្តីរិះគយគន់មើល ហើយមានព្រះបន្ទូលថា: "មកនេះ ក្ងានដ៏ប្រសើរ! ឲ្យខ្ញុំសុំស្ទាបស្លាបទន់ល្អិតដែលជាវត្ថុមួយអស្ចារ្យផង" ។ ប៉ុន្តែក្ងានហាក់ដូចជាគ្មានព្រួយសោះ វាចេះតែហែលចេញទៅៗ ។ ព្រះនាងទមយន្តីចង់ក្រសាលផងក៏ចេះតែតាមចាប់ផុតៗ ។ ពួកស្រីស្នំដែលនៅលើមាត់ច្រាំង ឃើញព្រះអង្គម្ចាស់ក្សត្រីដេញតាមក្ងានដូច្នោះក៏នាំគ្នាសើចសប្បាយ ។ ក្ងានអន្ទងព្រះនាងទាល់តែដល់លើវាលស្មៅមួយនៅក្បែរទឹក ហើយវាក៏ឈប់នៅទីនោះចាំព្រះនាងៗ

ទ្រង់រត់ឡើងពីទឹកដោយមានសេចក្ដីត្រេកអរជាពន្លឹក ហើយស្រែកបណ្ដើរផងថា: "ឯងទៅណាទៀត ម្ដងនេះអញចាប់បានឯងហើយ, នៅក្នុងទឹកឯងហែលពូកែជាងអញ ប៉ុន្ដែដល់គោកហើយ ឯងមិនមែនរត់ឈ្នះអញទេ" ។ ខណៈនោះស្រាប់តែក្ងានពោលពាក្យយ៉ាងស្រទន់ពីរោះឡើងថា "ទូលព្រះបង្គំជាខ្ញុំលែងរត់ទៀតហើយ ព្រះនាង! ព្រោះទូលបង្គំបានអន្ទងព្រះនាងឲ្យឆ្ងាយអំពីពួកស្រីស្នំហើយ, អស់រយៈដ៏យូរទើបគេមកដល់ព្រះនាង ។ បើដូច្នេះ សូមព្រះនាងទ្រង់ព្រះសណ្ដាប់ទូលបង្គំ, ទូលបង្គំជាខ្ញុំនេះ ជាអ្នកនាំរាជសារមកក្រាបទូលព្រះនាង: នៅឯប្រទេសនិសធ: មានស្ដេចមួយព្រះអង្គព្រះនាមព្រះបាទនល: សោយរាជសម្បត្តិ ទ្រង់ប្រកបដោយរូបឆោមលោមពណ៌ល្អ គ្មានអ្វីប្រដូចបាន កាលណាគេឃើញទ្រង់ គេតែងគិតថា ក្រែងតែគន្ទព៌ (Kandarpa) មកក្នុងខ្លួនបង់ ។ ទ្រង់មានព្រះទ័យក្លាហាន ហើយនឹងមានសន្តិភាពផង ពួកសត្រូវខ្លាចទ្រង់ណាស់ ។ ទ្រង់បានឮគេពោលពាក្យសរសើរព្រះនាងជាញយៗ ហើយទ្រង់កួចព្រះទ័យស្នេហាព្រះនាង បើសិនជាព្រះនាងបានព្រះអង្គជាព្រះស្វាមី ម៉្លេះសមព្រះនាងនឹងបានគាប់ប្រសព្វនូវសេចក្ដីសុខពិត ។ ទូលព្រះបង្គំធ្លាប់នៅឯសួគ៌នាយ ជាមួយនឹងព្រះអាទិទេពនឹងទេពកញ្ញា ប៉ុន្ដែទូលបង្គំនឹងថាព្រះអាទិទេពណាមួយល្អដូចព្រះបាទនល: ឬនឹងថាទេពកញ្ញាណាមួយល្អដូចព្រះនាងទមយន្តីគ្មានឡើយ ។ ក្នុង

បំណុកមស្រីទាំងអស់ ព្រះនាងទុកដូចជាវត្ថុមួយដ៏ថ្លៃថ្លា គួរតែអ្នកដែលមានសម្ភារភាពល្អឯតតៅប្រមៅសនាជាមួយនឹងអ្នកល្អឯត; ការប្រមៅសនាបែបនេះ នឹងបានសេក្ដីសុខ សេចក្ដីចំរើនដកប" ។ ព្រះនាងទមយន្តី ទ្រង់ព្រះសណ្ដាប់ក្ងានចរចាហើយព្រះនាងទ្រង់ញញឹម, មើលទៅមព្រះឱស្ឋនៃព្រះនាងទ្រង់ញញឹមបីដូចជាផ្កាទើបនឹងរីកថ្មីៗ ដែលមានសម្បុរស្រស់ប្រិម, ក្ងានក៏ឈប់ក្រាបទូល, ព្រះនាងទ្រង់ព្រះដំរិះដោយគន់ទៅស្ងៀម ។ បន្តិចមក ព្រះនាងទ្រង់អង្អែលក្ងាន ដែលមានស្លាបសម្បុរមាស ហើយទ្រង់មានព្រះបន្ទូលថា: "ក្ងានសម្លាញ់! ចូរឯងទៅក្រាបទូលព្រះបាទនាលៈវិញថា: បើព្រះអង្គមិនធ្វើងដៃទេ សូមស្ដេចទ្រង់យាងមកកាន់ប្រទេសព្រះបិតានៃព្រះនាងៗ នឹងមានសេចក្ដីត្រេអរជាពន្ទឹក" ។ ព្រះនាងលុះមានព្រះបន្ទូលហើយ ក៏បពោះអង្អែលក្ងានៗ ក៏ហើរសំដៅទៅនគរព្រះបាទនាលៈ ។

## វគ្គទី ៤

ព្រះនាងទ្រង់ចេះតែនឹកឃើញនូវសំដីក្ងានពៃ ពុំមានភ្លេចមួយវេលា ហើយទ្រង់បរិតក្កកន់ព្រះហឫទ័យថា: "អញមានគេស្រឡាញ់! អញមានស្ដេចមួយព្រះអង្គ ដែលមានរូបឆោមលោមពណ៌ល្អគ្មានពីរស្រឡាញ់" ។ ប៉ុន្តែលុះព្រះនាងទ្រង់នឹកឃើញថា: "ស្ដេចនោះគង់នៅឆ្ងាយពីព្រះនាងណាស់ កាលណាឡើយព្រះអង្គនឹងស្ដេចយាងមកដល់!

កាលណាឡើយព្រះនាងនឹងបានយល់ព្រះភក្ត្រព្រះអង្គ" ។ ព្រះនាងក៏ដកដង្ហើមធំហើយមានព្រះភក្ត្រស្រពោនជាទុក្ខខ្វល់ក្នុងព្រះទ័យ ។

ពួកស្រីស្នំទាំងអម្បាលមាណពុំយល់ហេតុ ដែលនាំឲ្យព្រះនាងកើតកង្វល់យ៉ាងនេះសោះ ។ នាងមលវិកា (Malavika) ដែលជាស្នំជំនិតបានទូលសួរព្រះនាងថា "ហេតុអ្វីបានជាព្រះនាងលែងញញឹមសប្បាយ: ព្រះនាងដ៏ប្រសើរ! ទ្រង់ដកដង្ហើមដោយលំបាក ខ្យល់ដែលបក់មកពីភ្នំ ហាក់ដូចជាមានសភាពធ្ងន់សង្កត់លើព្រះរូបព្រះនាងដែលខ្ពល់ក់ ។ កងដែលនៅនឹងកព្រះហស្ត នឹងកព្រះបាទនៃព្រះនាងក៏លែងបញ្ចេញខ្ញូវសំណូរយ៉ាងពីរោះតទៅទៀត ព្រះនាងបើមានវិតក្កអំពីរឿងអ្វី សូមព្រះនាងកុំទ្រង់លាក់រឿងហេតុនោះនឹងខ្ញុំម្ចាស់ថ្វី" ។ ប៉ុន្តែព្រះនាងនៅព្រងើយ ប្រហែលជាព្រះនាងគ្រាន់តែស្តាប់ពោលទៅទេ ក៏មិនដឹង ។ នាងមលវិកាចង់ជួយយកអាសាព្រះនាង ក៏រត់ទៅទូលព្រះបាទភិមៈជាព្រះវរបិតាថា: "បពិត្រព្រះករុណាថ្លៃវិសេស! សូមទ្រង់ព្រះមេត្តាប្រោស! ទ្រង់បានប្រគល់ខ្ញុំម្ចាស់នេះ ឲ្យនៅបំរើព្រះរាជបុត្រី ដោយប្រិយភាព ។ ប៉ុន្តែឥឡូវនេះ ខ្ញុំម្ចាស់មានសេចក្តីព្រួយជាខ្លាំងណាស់ ព្រោះព្រះនាងព្រួយព្រះហឫទ័យទាំងយប់ទាំងថ្ងៃ ។ ព្រះនាងមិនទ្រង់ឆ្លើយនឹងសំនួរខ្ញុំម្ចាស់សោះ ហើយទ្រង់ចេះតែគប់ប្រមល់នឹងការសព្វសារពើ ។ ព្រះនាងទ្រង់ប្រឈួនហើយ សូមទ្រង់ព្រះ

មេត្តាប្រោស! សូមទ្រង់យាងទៅមានព្រះរាជឧង្ការសួរព្រះនាងឲ្យទ្រង់ប្រាប់ថា ហេតុអ្វីបានជាព្រះនាងកើតទុក្ខ សូមទ្រង់ប្រោសប្រណីមើលព្រះនាងឲ្យជាសះស្បើយផង" ។ ព្រះបាទកិមៈ លុះទ្រង់ព្រះសណ្ដាប់សព្វសេចក្ដីហើយ ទ្រង់ខ្ទត់ទឹងព្រះរាជបុត្រី ទ្រង់យាងចេញយ៉ាងលឿនទៅកាន់ដំណាក់ព្រះនាង ហើយទ្រង់ទតយល់ព្រះនាងទមយន្តីគង់សំឡឹងទៅទីឆ្ងាយ ។ ចួនកាលព្រះនាងមានព្រះបន្ទូលជាប់ៗ ដូចគេហត់ ។ ព្រះនាងទ្រង់ក្រោកឈរឡើង ព្រះរាជាស្មានតែព្រះនាងឃើញទ្រង់ ។ តែព្រះនាងបែរព្រះភក្ត្រចេញមិនថ្វាយបង្គំទ្រង់ ព្រះនាងយាងពីរបីជំហាន ហើយទ្រង់ដាក់ព្រះអង្គគង់លើព្រះទែនសំរាកព្រះកាយវិញ ។ ព្រះរាជាមានព្រះឧង្ការថា: "ទមយន្តី កូន!..." ប៉ុន្តែទ្រង់យល់ថាព្រះនាងគ្មានស្ដាប់ទ្រង់ទេ ទើបទ្រង់គិតថា "តើនួនអញកើតអ្វីអេះ?" ហើយទ្រង់នៅតែសំឡឹងព្រះនាងគ្មានដាក់ព្រះនេត្រ ។ ព្រះនាងទ្រង់ក្រោកឈរឡើងទៀត ហើយទ្រង់គង់ទៅវិញដោយដកដង្ហើមធំ ។ មួយរំពេចនោះស្រាប់តែព្រះនាងក្រឡេកស្គាល់ជាព្រះវរបិតាក៏ស្ទុះទៅឱបព្រះបាទព្រះអង្គ ហើយមានបន្ទូលដោយសំឡេងខ្សោយថា "ឱ: ព្រះវរបិតា!" ប៉ុន្តែព្រះនាងមានព្រះបន្ទូលពុំទាន់ចប់ផងព្រះនាងក៏ទ្រង់ព្រះកន្សែង ។ ព្រះមហាក្សត្រទ្រង់មានព្រះឧង្ការយ៉ាងស្រួលទៅកាន់ព្រះនាងថា: "ម្នាលកូន! ព្រះបិតាដូចជាយល់នូវទុក្ខរបស់កូន

ក្នុងខណៈដែលកូនកំពុងតែពេញរូប-រាងយ៉ាងនេះ មិត្តភាពរបស់បិតាតែមួយ មិនជួនល្មមនឹងធ្វើឲ្យកូនសប្បាយចិត្តបានទេ ។ ថ្ងៃណាមួយក្នុងពេលឆាប់ៗនេះ បុរសដែលជាប្ដីរបស់កូននឹងមកនាំកូនចេញឆ្ងាយពីព្រះបិតាហើយ ព្រះបិតាគ្មានសិទ្ធិនឹងឃាត់ឃាំងឡើយ ។ ចូរកូនកុំយំថ្វីណាទមយន្តី ! ចាំព្រះបិតាប្រើទូតឲ្យទៅទូលស្ដេចក្នុងទ្វីបទាំងមូលឲ្យមកប្រជុំនៅក្នុងសន្និបាតដែលកូនស្រីត្រូវរើសប្ដី ដែលប្រកបដោយជោគជ័យដោយខ្លួនឯង" ។ ព្រះនាងទមយន្តី ក៏ស្ទុះរហ័សទៅឱបព្រះបិតាដោយមានកក្រើកញញឹមស្រស់ស្រាយ ។

វគ្គទី ៦

ពួកទូតចេញនាំសារទៅគ្រប់នគរ ហើយចូលទៅទូលស្ដេចគ្រងរាជ្យថា: "សូមព្រះករុណាជាម្ចាស់ជីវិតលើត្បូងទ្រង់ជ្រាប ដ្បិតព្រះនាងទមយន្តី ដែលជារាជបុត្រីព្រះបាទភីមៈ ដែលជាស្ដេចសោយរាជ្យនៅប្រទេសវិទភៈត្រូវរើសរកព្រះស្វាមី ព្រះករុណាជាម្ចាស់យើងខ្ញុំពល់គ្នាសូមឲ្យទ្រង់យាងចូលទៅក្នុងមហាសន្និបាតនោះ" ។

ពួកស្ដេចទាំងប៉ុន្មានដែលបានទទួលដំណឹងយ៉ាងដូច្នេះ ក៏រៀបព្រះអង្គឡើងគង់លើរាជរថដ៏វិសេស ព្រមទាំងមានក្បួនហែដ៏ស្កកស្កម្ភ ។

(មានត)

# ដំណើរអស្ចារ្យនៃលោកក៉ាស្វ៊ឹយូយេ

លោក យូកូគុស៊ី អ្នករៀបរៀង

លោក ប៉ាយ-ប៊ុក ក្រុមការ ប្រែពីបារាំងមកជាខ្មែរ

---

## កថាមុខ

ក្នុង គ. ស. ១៧៧១ នៅកោះស៊ីកូគុ (Shikoku) នៃប្រទេសជប៉ុន គេបានបោះពុម្ពផ្សាយនូវរឿងនេះ, អ្នកនិពន្ធនាម "យូកូគុស៊ី" - ជា- រហស្សនាម ប្រែថា "អ្នកស្រុកនៅជ្រោះភ្នំ" គឺជារឿងក៏ប្រែកបដោយ អច្ឆរិយភាព ដែលយើងបានបកប្រែមកចុះផ្សាយនៅទីនេះ ។ សៀវភៅ នោះនាមថា អ៊ីកូគុគីដង់ (Ikoku-Kidan) "រឿងព្រេងនៅស្រុកប្លែក" ។ រឿងនេះមានអ្នកនិពន្ធចំណានខាងប្រឡោមលោក នាម បាគិន (Bakin) បានយកមករចនាហាសិបឆ្នាំក្រោយមក ដាក់អត្ថបទថា "មុស៊ូប៊ីយូយេ" (Musobioyé) តែកិច្ចការដែលធ្វើទាំងប៉ុន្មានមិនសូវមានសារៈសំខាន់អ្វី ឡើយ ។ ដំណើរទីមួយនិងដំណើរទីប្រាំមួយ គេបានបកប្រែចុះក្នុង ទស្សនាវដ្ដី "Transaétions of the asiatic Soiéty of Japan" ពី គ. ស. ១៨៧៩ ។ ការបកប្រែនេះ គឺបកប្រែតាមលោក វ. គ្រែស្ត៍ស៊ុង (M. w. Cresvdson) ដែលបានចុះផ្សាយនៅក្នុងទស្សនាវដ្ដី (Nineteenth Century) ។ យើងសូមឲ្យលោក - អ្នកដែលពេញចិត្តខាងការស្វែងរក

នូវបញ្ហាខាងប្រកព្វទីមួយ ៗ នៃសៀវភៅនេះ អាននូវអារម្ភកថារបស់ លោកក្រស្តវ៍ស៊ុងចុះ! រឿងរ៉ាវក្នុងសៀវភៅនេះ ដូចគ្នានឹងដំណើរលោក ប្រកបដោយអមតភាពនៃគុលីវើរ (Gulliver) ចំពោះត្រង់ដំណើរទៅ ប្រទេសប្របឌិនញ៉ាក់ (Pays de Brobdingnac) គេបានឲ្យដំណឹងថា សៀវភៅដែលលោកស្វីហ្វត៍ (Swift) និពន្ធបានផ្សាយទៅដល់ប្រទេស ជប៉ុនជាសេចក្ដីបកប្រែភាសាហូឡង់; គឺសៀវភៅនេះ ដែលជាបុព្វហេតុ ឲ្យអ្នកនិពន្ធសៀវភៅអ៊ីកុគូរីដង់ បានយកមករចនាជារឿងព្រេងនេះ ៗ បើទុកជាយ៉ាងណាក៏ដោយ សៀវភៅនេះ សមរម្យនឹងយកមកអនុវត្តន៍ ខាងមជ្ឈដ្ឋានជប៉ុន ហើយយើងសង្កេតទៅប្រហែលជាសៀវភៅនេះ សម្រាប់រិះគន់ដោយស្ងាត់កំបាំងនៅសម័យបច្ចុប្បន្ននេះ ៗ មានសេចក្ដីខ្លះ ដូចជាពាក្យដែលមានលំនាំគួរឲ្យសើចរបស់លោកស្វីហ្វត៍ ហើយយោបល់ ដែលអ្នកនិពន្ធបានពណ៌នាកងដំណើរទៅប្រទេសយក្ស ដែលលោក វ៉ុលតែរ (Voltaire) បានយកទៅរចនានូវរឿងព្រេងនោះ គឺថាសៀវភៅ នេះមានឱជារសប្លែកអស្ចារ្យ ដែលជាហេតុឲ្យលោកអ្នកអានពេញចិត្ត មិនខាន ៗ

គ. សាំង-អ៊ីវ (G Saint.Yves)

## ១.— ដំណើរទៅកាន់អមតៈប្រទេស (Pays d'Immortalité)

ក្នុងកាលពិភពលោកសម្បូណ៌ដោយភោគទ្រព្យ ហើយប្រកបដោយសន្តិភាព នៅទីក្រុង នាគាសាគី (Nagasaki) ក្នុងខេត្តហ៊ីសេន (Hisen) មានមនុស្សម្នាក់នាម "ស៊ីកាយ៉ាវ៉ាសូប៊ីយូយេ" [hikaiya wasobioyé] ពូជវង្សត្រកូលរបស់លោកមានមកពីបុរាណកាល ជាសេដ្ឋីតាំងទីលំនៅ ១ ទីក្រុងនោះ ។ លោកជាចៅហ្វាយគ្រួសារជាទីគោរពនៃពាណិជ្ជដ្ឋានមួយ លក់ល័ក្តមកពីប្រទេសចិន និងហុល្លង់ ដោយមានអ្នកជំនួញបរទេសទៅមកជាញឹកញយ, ហើយលោកជាអ្នកប៉ុនប្រសប់ខាងនិពន្ធរឿងកំប្លែង ៗ ដល់ធ្វើជំនួញនោះបានចំរើនតាមលំដាប់ លោកបានប្រគល់ហាងនោះមកកូនប្រុសលោកនាម ស៊ុស៊ូ (Shuz] លោកអាយុបានសែសិបប្រាំបីឆ្នាំ លោកបានចាត់ឲ្យសង់គេហដ្ឋានមួយដោយឡែក ស្ថិតនៅជិតគ្រឹហាដើមរបស់លោក ហើយលះបង់ការងារទាំងអស់ចូលទៅនៅទីនោះ ។ លោកនៅតែម្នាក់ឯងជាមួយនឹងទាសីម្នាក់សម្រាប់ដាំបាយបរិភោគ ។ ដើម្បីនឹងសំរាកកំឡាំង លោកបានទៅធ្វើនេសាទត្រីជាកិច្ចកំសាន្ត ព្រោះលោកចូលចិត្តតាំងពីយុវកាលមក ។ ដំបូងលោកបានស្ទូចត្រីនៅលើមាត់សមុទ្រ តមកទៀតលោកមានទូកមួយអុំទៅកណ្តាលសមុទ្រ ។

នៅពាក់កណ្ដាលខែសីហា សម័យដែលព្រះចន្ទកំពុងពេញបូណ៌មី; ក្នុងពេលនោះ មានពួកអ្នកមានបំណោះច្រើនទៅលេងកំសាន្តនៅទីនោះ ៗ លោកវ៉ាស្ទូប៊ីយូយេ ដើម្បីចៀសចេញពីការជជែកគ្នា ចំពោះពួកបណ្ឌិតទាំងនោះដែលអួតអាងអំពីបំណោះរៀងខ្លួន លោកក៏ជិះទូកមួយដើម្បីនឹងទៅយកខ្យល់អាកាសតែម្នាក់ឯង ៗ បន្តិចព្រះចន្ទក៏រះឡើងភ្លឺចែងចាំងដោយរស្មីស្រទន់ នៅលើឫទឹងដើមស្រល់ ៗ លោកក៏បានទស្សនានូវពន្លឺភ្លឺទាំងនោះ ដោយពេញចិត្តពន់ពេក, ហើយអុំបណ្ដើរស្ងើចបណ្ដើរ ដល់ទៅចម្ងាយមួយយោជន៍ពីមាត់សមុទ្រ លោកបានឃើញពពកខ្មៅនៅលើនភាល័យ ៗ បន្តិចទៀត, វាយោបក់ឡើង ភ្លៀងក៏ធ្លាក់មក ៗ លោកបានចាំនូវសុភាសិតមួយកន្លែងថា: "មេឃក្នុងសរទរដូវប្រែប្រួលដូចចិត្តមនុស្សទៅទៀត" ៗ លោកក៏ប្រញាប់ប្រញាល់អុំវិលត្រឡប់មករកគោកវិញ តែមិនបានសម្រេច! វាយោធ្វើឲ្យរហែកក្ដោង កាច់បំបាក់ដងក្ដោង ហើយទូកក៏វិលទៅកាន់កណ្ដាលសមុទ្រវិញ ៗ បន្តិចទៀត, មេឃក៏កាន់តែងងឹត លោកវ៉ាស្ទូប៊ីយូយេលែងដឹងទិសតំបន់ អុំទូកជាការឥតប្រយោជន៍, ហើយលោកអស់កម្លាំងផង ៗ តែចិត្តលោកកាន់តែភ្លៀវភ្លាឡើង, លោកអង្គុយនៅក្នុងទូកហើយបណ្ដោយទៅតាមខ្យល់ព្យុះនាំទូកទៅកាន់ទីណាក៏ដោយ ៗ

លុះពេលបុព្វណ្ហសម័យនៃថ្ងៃទី ៤ ពាយោក៏ស្ងប់ ៗ លោកក៏ស្ទើបយូរយេ មិនប្រាបថាលោកស្ថិតនៅទីណាទេ ព្រមទាំងមិនស្គាល់ទិសណាដែលលោកបំរុងនឹងចែវទៅ , លោកក៏បណ្ដែតទូកលោកទៅតាមទំនើងទឹកហូរ ហើយលោកបំណងនឹងរស់នៅក្នុងពេលនោះដោយការនេសាទត្រី ដូចជាលោកសង្ឃនាម សុនក្កាន់(១) នៅលើថ្មមួយនៃកោះដែលមានព្រះពាយបក់បោកជាខ្លាំង ៗ ក្នុងរយៈវេលាបីខែ, ទូកនោះបានអណ្ដែតទៅដល់ភូមិភាគមួយដែលលោកសន្មតថា "សមុទ្រកក់" (Mer de Boné) ដែលគ្មានពាយោនឹងរលកសោះ ៗ ហើយក្នុងពេលនោះ លោកឃ្លានបាយពន់ពេក ៗ ដប់ថ្ងៃក្រោយតមក លោកស្ថិតនៅក្នុងទូករង់ចាំតែសេចក្ដីស្លាប់មកដល់ ៗ ក្នុងមួយរំពេច, លោកដូចជាមានកំឡាំងថ្មីដោយមានព្រះពាយបក់នាំក្លិនក្រអូបមកពីទីមួយ ៗ លោកក៏ងើបក្បាលឡើង, ក្រឡេកទៅឃើញដី, ក៏ចែវទូកដើម្បីទៅឈប់នៅទីនោះ ៗ លោកមានចិត្តឆ្ងល់ពន់ពេកថាដល់លោកអញ្ជើញជិតទៅដល់ទីនោះ លោកទៅជាមានកំឡាំងថ្មីឡើងវិញ ; លោកក៏ខំចែវហូតដល់មាត់សមុទ្រ ៗ ដល់លោកឡើងទៅលើគោក , លោកស្វែងរកទឹកបរិភោគសិន , លោកបានទៅប្រទះនឹងទឹកសនៀមមានទុជារសប្លែកអស្ចារ្យ លោកអាស្រ័យ

---

(១) លោកសង្ឃខ្មាមក្នុងសតវត្ស ១២ ដែលគេដាក់ទណ្ឌកម្មនិរទេសចេញពីស្រុកទៅស្លាប់កណ្ដាលកោះសមុទ្រ ។

ទឹកនោះច្រើននាំឲ្យលោកសប្បាយចិត្ត លែងនឹកនាទូវទុក្ខព្រួយពីកាលមុន ។ លោកបានឡើងទៅលើភ្នំតូចមួយហើយក្រឡេកមើលទៅគ្រប់ទិសដំបន់ដីឃើញថាខ្លួនស្ថិតនៅកន្លែងប្រទេសមួយ ដែលមានត្រឹមតែវត្តមួយ ។ ប្លែកពីវត្តដែលមាននៅប្រទេសជប៉ុន ថែមទាំងធម្មជាតិនោះ មានសភាពស្អាតល្អមួយរយស្មួនទៅទៀត ។

ពួកប្រជាករដែលមកហោមរោមជុំវិញលោកក្នុងមួយរំពេច លោកបានសាកសួរពួកនោះដោយពោលពាក្យជាភាសាចិនសុទ្ធ តែប្រជាជនទាំងនេះ នៅស្ងៀមស្ងាត់មិនអាចឆ្លើយតបតអ្វីឡើយ ។ លោកនៅទីនោះ ប្រៀបដូចជាមៀមដែលមានហ្វូងឆ្កែហោមរោម, តែលោកមានភ័ព្វសំណាងទទួលជួបនឹងមនុស្សម្នាក់ ប្រហែលអាយុជាងសែសិបឆ្នាំកពុងញែកចូលមកជិតលោក ហើយក៏សួរមកលោកជាភាសាចិនថា លោកអញ្ជើញមកពីណា? ។ លោកក៏ពណ៌នាជំរាបអ្នកនោះអំពីព្រឹត្តិការណ៍សព្វគ្រប់ហើយ អ្នកនោះបានសរសើរថា "លោកមានភ័ព្វល្អណាស់បានអញ្ជើញមកដល់ប្រទេសនេះ នាមថា: អមតៈប្រទេស ស្ថិតនៅព្រំមួយម៉ឺនយោជន៍ពីប្រទេសជប៉ុន ។ ខ្ញុំឈ្មោះស្វ-ហ្វ-គុ (Jofoku) ហើយព្រះអធិរាជប្រទេសចិនព្រះនាមស៊ីស្វ (Shisko) ស្តេចកែលចកែហើយជាចណ្ឌាល បានចាត់ខ្ញុំជាគ្រូពេទ្យឲ្យមកកាន់ទីនេះ ដើម្បីនឹងស្វែងរកទឹកម្រឹត្យ (ទឹកដែលធ្វើឲ្យអាយុវែង, (elixer de Congue vie) ។ ខ្ញុំ

បានមកក៏ឃើញនូវទឹកអម្រឹតនេះ, តែខ្ញុំយល់ថាគួរឲ្យស្អប់ខ្ពើមនូវការធ្វើឲ្យបណ្ដាកជបានអមតភាព ធ្វើចិត្តខ្ញុំមិនឲ្យវិលត្រឡប់ទៅកាន់ប្រទេសវិញ ។ លោកអាចពិសោធន៍បានថានៅទីនេះគេអាចរស់នៅបានជានិរន្តរ៍ ហើយមិនដែលមានរោគាពាធសោះឡើយ" ។

– លោកហ៊ីស៊ូប៊ីយូះយ ឆ្លើយតបទៅវិញថា: ខ្ញុំទុកជាមានភ័ព្វសំណាងល្អដែលបានមកសន្ទនាការនឹងបណ្ឌិត ស៊ូហ៊ូគុ ដែលខ្ញុំបានអានសៀវភៅរបស់លោកជាច្រើន ។ ខ្ញុំបានឮគេពោលពីអមតៈប្រទេស តែខ្ញុំមិនៈជឿអ្នកណាហោះឡើយ" ។ សេចក្ដីឆ្លើយនេះ ធ្វើឲ្យលោក ស៊ូហ៊ូគុ សប្បាយចិត្តពន់ពេកទាល់តែលោកស្រែកថា: "បើប្រទេសជប៉ុនជាសមន្ដប្រទេសនឹងប្រទេសចិន សូមលោកចូលមកនៅក្នុងគេហដ្ឋានខ្ញុំប្រៀបដូចជាគេហដ្ឋានរបស់លោកចុះ" ។ លោកហ៊ីស៊ូប៊ីយូយក៏ធ្វើតាមបង្គាប់នៃលោក ស៊ូហ៊ូគុ ។ លោកហ៊ីស៊ូប៊ីយូយបានស្ថិតនៅទីនោះ រពងពីរឬបីសតវត្សជាទីគោរពកប់អាន ហើយមានសិទ្ធិចេញទៅពិនិត្យនូវកិច្ចការនឹងអកប្បកិរិយាពួកប្រជាជន ដែលនៅក្នុងអមតៈប្រទេស (ដែលមនុស្សមានសភាពដូចគ្រលទើបអាយុ ៤០ ឆ្នាំ) គ្រប់គ្នា ហើយមិនដែលមានគាំពារសោះឡើយ ។ ក្នុង ១០០ ឆ្នាំម្ដង ដូនកាលមានមនុស្សកើតឬស្លាប់ដោយមិនដឹងហេតុមកពីណា ហើយព្រឹត្តិការណ៍ថែមនេះធ្វើឲ្យប្រជាកស្ត្រជ្រួលជ្រើមពន់ពេក ។ អាកាសត្រជាក់ស្រួលៈ ភ្លៀង

ព្រះអាទិត្យផ្លាស់វេនគ្នាដោយសមភាគ មានផលានុផលសម្បូណ៌ ។ សត្វក្រសាគេបង្ហាត់ឲ្យចេះភ្ជួររាស់ស្រែចម្ការ ហើយអាចទំមដឹកទំនិញឥតរ៉ាន់បាន ។ លោកក៉ាស៊ូប៉ឺយូយេ បានរៀនជិះបក្សានោះជាយានជំនិះថែបថ្មី ហើយក៏ធ្វើដំណើរទៅក្នុងប្រទេសនោះ ទស្សនានូវទីកន្លែងដែលមាននាមល្បីល្បាញ ។ លោកបានឃើញកន្លែងមួយដាំមង្ឃុតជប៉ុន (pêcher) ជាច្រើន នៅជិតទីក្រុង ។ នៅទីនោះ មានសង់ភោជនាគារ រោងល្ខោន នឹងរបាំផ្សេង ៗ នៅជិតនោះមានភ្នំតូចមួយមានដាំរុក្ខជាតិកាមេលីយ៉ា (Camélias) ផ្កាក្នុងមួយពាន់ឆ្នាំម្ដង ។ ក្នុងពេលនោះ ជាឱកាសដែលប្រជារាស្ត្រទាំងមូលស្លៀកខោអាវស្អាតមកពីគ្រប់ទិស ជិះសត្វក្រសាដែលលោកក៉ាស៊ូប៉ឺយូយេបានប្រៀបធៀបថាដូចហ្វូងទាព្រៃហើរលើអាកាសក្នុងសរទរដូវ ។ អ្នកទាំងអស់បានគ្រប់នូវរសជាតិនៃជីវភាព ដោយឥតមានភ័យតក់ស្លុតនឹងទុក្ខនឹងសេចក្ដីស្លាប់ ។

តែដោយទេសកាលមានគេយកទៅក្នុងកោះនោះ នូវសៀវភៅគម្ពីរព្រះពុទ្ធសាសនាដែលពណ៌នាពីសេចក្ដីសប្បាយ ខាងស្ថានសួគ៌ពួកប្រជារាស្ត្របានអាននូវគម្ពីរទាំងនោះ ដែលអធិប្បាយអំពីសម្បត្តិទិព្វនៅស្ថានសួគ៌បានយល់ថាជីវភាពនៅលើផែនដី មានសភាពតែដដែល ៗ ចិត្តទៅជានឿយណាយនឹងគ្រឿងអាមិស ក៏មានបំណងចង់លះបង់ជីវិត ។ បុគ្គលណាដែលធ្វើមរណភាព គេទុកបុគ្គលនោះជាសប្បុរស ហើយ

សេចក្ដីមរណៈ គេទុកជាមន្តអាគមដ៏វិសេសដែលអ្នកចាំងអស់ទាំងស្រុងរក ដោយការណ៍ពិចារណានូវសន្ធារធម៌ ទៅក្នុងព្រៃតែម្នាក់ឯង ឬធ្វើទុក្ខខ្លួនឯងផ្សេងៗ ៗ អ្នកចាំងអស់នោះមិនអាចបរិភោគនូវផ្លែរាំងសេង (Ginséng) ដំឡូងផុកំងព្រៃ អន្ទង់ឬមា ជាម្ហូបដែលមានរុជារសឆ្ងាញ់ពិសា ៗ ពិតមែនតែម្ហូបអាហារចាំងនោះសម្បូណ៌ហើយថោកផងប្រ-ជាកស្ត្រចាំងប៉ុន្មានក៏មើលងាយនូវអាហារនោះ ថាជាទុសថពុលអាចធ្វើជីវិតឲ្យរស់នៅអស់កាលយូរ ហើយមានតែពួកទុគ៌តដែលគេប្រមូលរបស់ចាំងនោះមកសំចៃទុកក្នុងគេហដ្ឋាន ៗ ពួកសេដ្ឋីពេញចិត្តខាងវត្ថុដែលធ្វើឲ្យមរណៈឆាប់ដូចជាត្រីព្រះចន្ទ (poisson de lune) ដែលមានពិស ៗ នៅប្រទេសនោះ មនុស្សណាដែលបរិភោគត្រីព្រះចន្ទមានរសជាតិដូចខ្លាញ់គោ ឬកំកេមមួយបែប (cant harides) គេយកមករចនាទៅតាមរបៀប មិនអាចធ្វើខ្លួនឲ្យមរណៈបាន គ្រាន់តែធ្វើឲ្យមានរោគក្នុងរយៈវេលាកន្លះម៉ោង តែប៉ុណ្ណោះ បុគ្គលនោះទៅជាព្រៀងកំសប្បាយ ដោយមានគំនិតថាអញមុខជានឹងស្លាប់មិនខាន ហើយសភាពយល់បែបនេះធ្វើឲ្យមានហសនចិត្តពន់ពេក ៗ ដល់ថ្ងៃចូលឆ្នាំ, ឬពេលដែលមានធ្វើបុណ្យធំ ដើម្បីនឹងឲ្យសេចក្ដីឧបទ្រពមកដល់ខ្លួន, ប្រជាជននាំគ្នាដំឡោះរាំយឆាទន៍ (paravent) លើក្រោមៗលើ, រាំងនឱជាក់បញ្ច្រាសហើយស្មៀកពាក់ខោអាវកាន់ទុក្ខ ៗ លិខិត

សំដែងទៅសេចក្តីសោកស្តាយ ជាលិខិតប្រសើរបំផុតដែលត្រូវបញ្ជូនទៅមិត្តភក្តិក្នុងពេលចូលឆ្នាំ ហើយជាកិច្ចមិនសមគួរបើផ្ញើលិខិតទៅឲ្យពរសព្ទសាធុការ ក្នុងពេលនោះចំពោះបុត្រធីតា ។ ការគួរសមគឺគេបញ្ជាក់ឲ្យដឹងថាខ្លួនមានសុខភាពមិនសូវបរិបូណ៌ ហើយថាខ្លួនជិតដល់ពេលក្ស័យជីវិតដែលបិតាមាតាមានចិត្តកែកព្រួយពន់ពេក ។

មុនដំបូងលោកក៏ស្ទីយូយេ យល់ថាជាទំនៀមនេះប្លែកអស្ចារ្យ ហើយទៅជាមានចិត្តសប្បាយចំពោះសុខភាពដ៏ល្អ នឹងអមតភាពរបស់លោកទៅវិញ, លុះលោកនៅទីនោះប្រហែលពីរសតវត្ស លោកទៅជាអផ្សុកដោយជីវភាពមានលក្ខណៈដដែល ៗ ។ លោកបានយកបញ្ហាទាំងនេះទៅពិចារណា, លោកក៏យល់ច្បាស់ថាមិនដែលមានមនុស្សណាស្លាប់ ។ ការដែលគ្រស្លាប់ជាហេតុញាំងលោកឲ្យមានបំណងចង់ស្លាប់, លោកពិសោធន៍ខ្លួនលោកមុជទឹកឲ្យលង់លិច, លោកបណ្តែតខ្លួនលោកដូចឆ្នុកដប ហើយលោកគិតលោតទឹកឲ្យស្លាប់ តែដល់លោកទៅ ខ្លួនលោកធ្លាក់ដូចឆ្នា លោតពីបពង់ទឹកខាងលើ ។ ការពិសោធន៍ទាំងប៉ុន្មានបរាជ័យធ្វើឲ្យលោកកាន់តែព្រួយបារម្ភជាខ្លាំង; តែលោកមានបំណងចង់យកអមតភាពរបស់លោកមកអនុវត្តនាការ ដើម្បីទឹងចេញពីអមតៈប្រទេសទៅទស្សនាប្រទេសផ្សេង ៗ ហើយនឹងនិពន្ធពីទំនៀមទម្លាប់ប្រជាកស្ត្រីដែលនៅប្រទេសទាំងនោះ ។ ដល់លោក

កំណត់ក្នុងចិត្តប្រែប្រួល, លោកក៏បានយកនូវសោកណាភាពនៃជីវិតដែលរស់នៅ, លោកក៏ខំបរិភោគអាហារឆ្អែតស្កប់ស្កល់ ដែលជាហេតុនាំឲ្យប្រជាកស្ត្រទាំងប៉ុន្មានចំអកឲ្យលោក ។ លោកក៏បានសរសេរសំបុត្រថ្លែងអំណរគុណចំពោះសប្បុរស ដែលលោកបានពឹងពាក់អាស្រ័យ, លោកលួចក្រសាមួយដែលមានស្លាបមាំទាំង ហើយក៏ជិះក្រសានោះតម្រង់ទៅទិសខាងត្បូង ។

## គតិអ្នកនិពន្ធ

ក្នុងពេលចូលឆ្នាំថ្មី, ជនជាតិជប៉ុនបានតុបតែងគេហដ្ឋាននឹងអក្សរសន្ទនាមថាអាយុវែង, ហើយមិនព្រមសរសេរពាក្យថា "បួន" ដែលមានសូរសំឡេងថា "ស្លាប់" ។ យើងព្រមទាំងសត្វតិរច្ឆានទទួលនូវសេចក្ដីស្លាប់ តែមិនសមទៅតាមវិចារណញ្ញាណសោះឡើយ ។ ដល់ក្រោកពីនិទ្រាឡើង យើងត្រូវធ្វើការលំបាកហើយនឹងតស៊ូនូវសេចក្ដីទុក្ខជាច្រើនប្រការ; បើយើងនិទ្រាលក់ រូបកាយយើងសម្រាកហើយ ចិត្តយើងលះបង់នូវការបលិពោធក្នុងលោក ។ ចំពោះន័យនេះសេចក្ដីមរណៈជាកម្រៃហើយអ្នកដែលក្ស័យជីវិតរួចខ្លួនឯងថា ហេតុម្ដេចក៏ខ្លួនយើងមិនស្លាប់ពីកាលមុន បើសេចក្ដីស្លាប់ស្រួលងាយយ៉ាងដូចនេះ ។ លំអនៃបុប្ផរស្មីព្រះចន្ទធ្វើឲ្យយើងសប្បាយចិត្តពន់ពេក ព្រោះវត្ថុទាំងនេះមិននៅស្ថិតស្ថេរចិរកាល តែងតែរស់នៅរួចស្លាប់ជាធម្មតា, បើវត្ថុទាំងនេះស្ថិតនៅ

ជានិរន្តរគ្មានអ្នកណាចង់មើលចង់ឃើញទេ ។ ដូចគ្នានឹងមនុស្សមិនចេះស្លាប់, មនុស្សនោះ លែងសប្បាយនឹងជីវិតដែលរស់នៅរាល់ថ្ងៃ ហើយមុខជាថ្ងូររងំក្រោយដែលធ្វើមរណកាល ដូចជាប្រជាជននៅអមតៈប្រទេស ។ មានតែអ្នកណាដែលមានជីវិតរស់នៅដោយសុខស្រួលជាមួយនឹងយើងអាចខ្លាចសេចក្តីស្លាប់ជាធម្មតា ។ មានពួកសេដ្ឋីជាច្រើនដែលមានរូបកាយមាំមួន អាស្រ័យឱសថឲ្យគេបំរើច្របាច់គក់ ហើយយកមកអុជសរសៃ (Moxas) លោកទាំងនោះអាចជ្រាបបានថា ថ្នាំកែរោគគឺសម្រាប់អ្នកឈឺពិត ៗ ហើយមិនត្រូវយកមកប្រើសម្រាប់អ្នកឈឺមិនពិតនោះទេ ។ បើអ្នកឯងអាពាធត្រូវអញ្ជើញគ្រូពេទ្យមកពិនិត្យសមុដ្ឋានរោគ ហើយត្រូវប្រតិបត្តិតាមពាក្យដែលលោកគ្រូពេទ្យបង្គាប់, កុំឲ្យទុករោគនោះឲ្យយូរទៅអនាគត, ដោយហេតុថារោគនោះស្រាលនៅឡើយ, មិនត្រូវនឹងដាក់ឱសថភ្លាមទេ បើអ្នកប្រព្រឹត្តយ៉ាងដូចនេះ, រោគនោះអាចមានអានុភាពខ្លាំងក្លាឡើង ហើយដល់ចង់ដាក់ឱសថ ។ នោះក៏ទៅជាមិនបានការគ្មានផល ។ ចូរអ្នកពិចារណាទូរទុកនៃអមតៈប្រទេស ហើយចូរអ្នកតាំងចិត្តកុំឲ្យតក់ស្លុតនឹងសេចក្តីស្លាប់ អ្នកមិនត្រូវចង់បានស្ថានភាពជាពួកអមតៈបុគ្គលទេ ។ ចូរអ្នករស់នៅដោយចិត្តសន្តោសហើយខំរក្សាចិត្តនោះឲ្យស្ងប់ស្ងៀមនឹងនួនដូចកំពូលភ្នំដូចនោះ ។

(មានត)

# ដំណឹងតាមខ្យល់ក្នុងកន្តារៈ

## លោកផេង-ជ្រឹវ សាស្ត្រាចារ្យនៅសាលាគរុវិជ្ជាភ្នំពេញ

*ប្រែពីភាសាបារាំងមកជាភាសាខ្មែរ*

---

## អ៊ី-ស្មាអ៊ីល

ព្រះអាទិត្យចាំងពេលខ្សាច់ឡើងក្តៅដូចគេដុត គឺពេលកណ្តាលថ្ងៃត្រង់ ៗ ផ្លូវទឹកខ្វះ រកធំដោយសារក្បៀងច្រើនក្នុងទិសាយៈផ្លូវ ក៏ហូរក្រវេចក្រវក់ចេញពីពួកភ្នំ ( ហាម៉ូត ) កាត់ព្រៃត្នោត ធ្លាក់ចុះក្នុងឈូង នាំទឹកថ្លាដូចកញ្ចក់ទៅលាយជាមួយទឹកសមុទ្រខៀវស្រងាត់ ៗ

ពេលនោះក្តៅណាស់ ហាក់ដូចគេយកសំណកំពុងពុះមកចាក់បង្ហូរពាសវាលពាសកាលលើព្រះធរណី ៗ ក្រុងអារ៉ាប់តូចមួយឈ្មោះកាសិ-កាព៉ូលី ហាក់ដូចជាដេកលក់ស្ងាត់ប្រៀបបញ្ជង់ក្រោមអណ្តាតភ្លើងគឺកំដៅព្រះសុរិយា ហើយឃើញតែស ៗ ភ្លឺ ៗ ដោយត្រូវចំណាំងថ្ងៃ ៗ ក្នុងសម័យដែលរឿងនេះកើតឡើង ជនជាតិអារ៉ាប់ក្រុងកាសិ-កាព៉ូលី ចំណុះសាសន៍តួរគី ៗ

មេក្រុមព្រមទាំង កាអ៊ិត បានប្រឹក្សាគ្នាថា ពេលនេះត្រូវតែយើងចុះចូលនឹងពួកទ័ពសិន តែយើងកុំចូលដៃជាមួយ ៗ ត្រូវយើងធ្វើឲ្យស្ងួត ៗ នេះគឺជាឧបាយមួយយ៉ាងសំខាន់ដើម្បីវៀរចាកការប្លន់ដណ្តើម

យកទ្រព្យរបស់ដោយបទកំហែង នឹងរក្សាកុំឲ្យមានសេចក្តីស្លាប់ដល់ជនជាតិអ្នកស្រុកអាយតតប្រយោជន៍ ហើយត្រូវឲ្យអ្នកទាំងអស់ទទួលស្គាល់អំណាចទ្មិលតែខាងក្រៅ អត់ចាំ មិនយូរប៉ុន្មានគង់មានថ្ងៃសងសឹកនឹងមកដល់ ៗ

ហេតុដូច្នេះ ប្រជារាស្ត្រអារ៉ាប់គ្រប់ៗ គ្នា យកចិត្តទុកដាក់គោរពច្បាប់ទ្មិលទាំងអស់ ៗ គ្មាននរណាម្នាក់ស្លាប់សោះ ហើយពួកមេទ័ពតួរគីក៏ព្រមទទួលរក្សាទំនៀមទម្លាប់ស្រុករបស់កាអ៊ិតទុក មិនមានចិត្តឈ្លានីះនឹងមិនត្រូវការធ្វើទុក្ខបុកម្នេញដល់អ្នកស្រុកអាយ ឬក៏ប្រើឲ្យអ្នកណាចាប់យកក្មេងចាស់មកវាយបែកឈាមនោះគត់មានឡើយ ៗ

តាំងពីឆ្នាំកាន់ប្រនោះមក ថ្ងៃនឹងខែ បេះតែកន្លងទៅៗ នាំយកទាំងសេចក្តីសុខទុក្ខគ្រប់គ្នាទៅជាមួយផង ៗ តំបន់ទាំងមូលហាក់ដូចជាសុខសាន្តត្រាណពិតប្រាកដ តែដែលតាមការណ៍ពិត គឺស្ងៀមស្ងាត់តែក្រៅទេ ព្រោះអារ៉ាប់យកសេចក្តីគោរពនឹងការគួរសមមកជារបាំងពីក្រៅ ចំណែកចិត្តខាងក្នុងនៅតែមានគំនុំជាធម្មតា ៗ

ក្នុងសម័យនោះ គេបានឲ្យការណ៍ជាច្រើនដែលថា នៅនាតំបន់ភ្នំមានការបះបោរគ្រប់ភូមិ ជនជាតិអារ៉ាប់ដើររេសនាំគ្នាដើរកេតក្សាតពេញទាំងលើខ្នងភ្នំ សម្លាប់ពួកអ្នកយាមល្បាតតួរគីឥតត្រាប្រណី មកពីមានជាតិក្រិកនាំយកគ្រឿងអាវុធនិងស្បៀងផ្សេង ៗ មកលបលួចលក់ឲ្យ ៗ

សូម្បីនៅទីក្បែរៗ ក្រុងក៏ដោយ តែងមានពួកអ្នកយាមស្លាប់ដោយដាច់ក តាមពិនិត្យទៅ ឃើញថាពួក៖ទាមយកដាវតូចៗ សណ្ឋានដូចកណ្តៀវមកពិឃាត ព្រោះឃើញមានក្បាលដាច់ចេញពីដងខ្លួន ។

និយាយដោយសង្ខេប គឺពួកពលករកងស្ពឺណុបមានសេចក្តីរំភើបយ៉ាងខ្លាំង ។ ផ្សិតស្រុកដែលទុកចិត្តថាជាសុខសាន្តត្រាណហើយ ត្រឡប់ជាមានការចលាចលខាងក្នុងយ៉ាងខ្លាំង វេលាដែលខាងក្រៅមានអាការបំពានដោយប្រើសត្តិភាព នឹងសេចក្តីអត់ទ្រាំនៅក្រោមនឹមសង្កត់ពីលើ ដូចជាភ្លើង ត្រជាក់តែខាងក្រៅ ចំណែកខាងក្នុងនៅក្តៅដ៏ជានិច្ច ដោយអាស្រ័យការត្រួតត្រាអយុត្តិធម៌របស់ទ្វិល ព្រោះអំពើល្អរបស់ទ្វិលថយៗទៅ ក្លាយទៅជាតម្រូវឲ្យធ្វើសេដ្ឋកិច្ចបានតែខាងក្នុងប្រទេស នឹងតម្រូវឲ្យជួយធ្វើទាហានខានមិនបាន មានបង្កើតការទារប្រាក់ពន្ធពល-ឆ្នាំ ជាកិច្ចនាំឲ្យរវល់តែនឹងពលករ ហើយការពេបជ្រាយចំពោះទំនៀមទម្លាប់ស្រុកក៏កាន់តែមានឡើង ប្រសិនបើមានជំទាស់អ្វីបន្តិចបន្តួចដល់ពលករ មានតែចាប់សាមីខ្លួនយកមកបាញ់ចោល មិនសូវមានការជំនុំជំរះរកខុសត្រូវតាមផ្លូវយុត្តិធម៌ឡើយ ។

ប៉ុន្តែក្នុងឱកាសនោះ នៅក្រុងកាស់ - កាក់ប៊ូលី ការបះបោរមិនទាន់ឃើញមានសំដែងអាការឲ្យលេចចេញច្បាស់នៅឡើយ ។ មហា-កាអ៊ិតក្រុងតូចនេះ នៅក្រោមអាណាព្យាបាលសាសន៍ទួគីព្រមទាំង

ប្រជាកស្ត្រមានសេចក្តីគោរពដ៏អស្ចារ្យ និងការទុកចុកចិត្តទៅលើ គំនិតនាយចៅហ្វាយរបស់ខ្លួនទាំងអស់ ។

តាំងពីប៉ុន្មានសតវត្សមកហើយ វង្សត្រកូលស្តាបនានៅស្រុកនេះ បានបន្តទំនៀមទម្លាប់និងសេចក្តីគំនិតចំពោះសាសនាគ្រប់តាំងពីអាពុក ដល់កូនជាច្រើនជំនាន់មកហើយ តាមពាក្យចាស់ទុំបរាបរៀងមក ។

ជនជាតិអាភ័ប់ កាលសម័យដើម ធ្លាប់មានថ្វីដៃ បានគ្រាប់ទៅក្នុង សាគរគ្រប់ទិស ហើយចេញបាកកំពង់ធំ ៗ ទៅដើរវាយយកស្រុកបំណុះ ក្នុងសាកលលោក ព្រមទាំងបានកសាងប្រាសាទស្តុកស្តម្ភទុកជាអនុស្សាវរីយ៍ក្នុងទីនេះខ្លះ ក្នុងទីនោះខ្លះ ដែលជាអមត្តកិច្ចក្នុងអតីតកាល ហើយ ពួកប្រជាកស្ត្រតែងរីករាយចំពោះកេរ្តិ៍ដំណែល ដ៏ជ័យជំនះនោះ ៗ ប៉ុន្តែ ឥឡូវនេះ សម័យប្រកបដោយកិត្តិយសសាបរលាបផុតរលត់អស់ហើយ ។

ទោះបីបានប៉ះពាល់ច្រឡូកច្រឡំ ជាមួយវឌ្ឍនធម៌នៃបច្ចិមប្រទេស ដែលយកគ្រឿងប្រស់ព្រៃដ៏ខ្លាំង សម្រាប់បន្ទន់ចិត្តមកផ្សព្វផ្សាយនាយ និងកេរ្តិ៍ទឹកក្រអូប ក៏ពួកចាស់ព្រឹទ្ធាចារ្យ ពួកកាអុិត ពួកលោកសង្ឃ ពួកប្រជាកស្ត្រដែលអាស្រ័យនៅក្រោមដំបូល ក្នុងភូមិ ក្នុងព្រះវិហារ មិន ស្ងាប់គំនិត នៅតែនឹកមិនភ្លេច ថាពេលវេលាតែងវិលដូចកង់រទេះ គង់តែគំនិតប្រាជ្ញាទំនៀមទម្លាប់របស់បុព្វបុរសប្រទេសត្រូវត្រឡប់មកទាំងមូល វិញជាមិនខាន ។

ហោរបានទំនាយទុកមកដែរថា ក្នុងស្រុកនឹងមានវិកល៍ គឺមួយសាសនាក្របៀងប៉ាំងបង្ខំស្រីផ្កាយអាកាប់ ។ ប៉ុន្តែមួយនេះមិនឋិតថេរនៅបានប៉ុន្មានសតវត្សឡើយ គង់មានថ្ងៃណាមួយ គូរង់ (សាសនាមហាម៉ុត) នឹងមានជ័យ ខាងចុងបំផុត គ្មាននរណាអាចផ្តាញ់បាន ហើយពួកទិល ត្រូវពួកអាកាប់ដេញចេញពីទឹកដីដែលទេព្តាបានជ្រើសសំរាំងទុកឲ្យនេះ ។

ក្នុងពេលនោះ ដើម្បីនឹងតាំងពួកទិលឲ្យបានឈ្នះ មិនត្រឹមតែតាំងចិត្តឲ្យមានក្លាហានជានិច្ចទេ ថែមទាំងត្រូវពិនិត្យពួកទិលឲ្យស្គាល់ជាក់ប្រាកដពីកម្លាំងនឹងការខ្សោយផង ។ ការសំខាន់ គឺត្រូវសំដែងទឹកមុខស្រស់ញញឹមជាក់ នឹងមានការទទួលពត់ទាក់កុកយ គឺថាត្រូវធ្វើជាគោរព ជាបំណុះដោយពិត ចំណែកគំនិតនឹងចិត្តត្រូវតែកុំទទួលស្គាល់ទាំងអស់ ។

ហេតុនេះ លោកកាអ៊ិត ព្រះនាម អៃយ៉ាដ ជាចៅហ្វាយធំក្នុងក្រុងកាសិ-កាប៊ូលីដែលប្រកបដោយសប្បុរសធម៌ បានបញ្ជូនកូនច្បងរបស់លោកឈ្មោះអ៊ីស្មាអ៊ីល ឲ្យទៅសំណាក់អាស្រ័យអស់អំឡុងជាច្រើនខែក្នុងប្រទេសអ៊ឺរ៉ុប ដើម្បីសង្កេតទូរដើមកំណើតទំនៀមទម្លាប់ប្រទេសនោះៗ ហើយនឹងឲ្យឆាយគិតពិចារណាអំពីបទនយោបាយ ។

មនុស្សទាំងអស់ក៏ចូលមតិគ្នាសុខចិត្តតាមលោកអៃយ៉ាដ ព្រោះគេចូលចិត្តថាត្រូវឲ្យស្គាល់របៀបវឌ្ឍនធម៌ប្រទេសបច្ចិមាឲ្យសព្វគ្រប់ ឲ្យ

ច្បាស់លាស់ដើម្បីនឹងឆាយកំបាត់ ។ ប៉ុន្តែមានហេតុកំបាំងមួយដែលលោកអៃយ៉ាដ នឹងអ្នកជិតខាងមិនបានប្រុងទុកជាមុន ។

វប្បធម៌ប្រទេសបច្ចិមា ទំនៀមទម្លាប់និងគំនិតរបស់សាសន៍អឺរ៉ុបមានអានុភាពដ៏អស្ចារ្យអាចធ្វើកិរិយាមារយាទនៃអ្នកកំឡោះ អ៊ីស្មាអ៊ីលឲ្យប្រព្រឹត្តតាមបាន ។

អ៊ីស្មាអ៊ីល បានសំណាក់អាស្រ័យក្នុងទីក្រុងធំៗជាច្រើន ហើយមិនអាចអត់ទ្រាំនឹងសេចក្តីត្រេមកដ៏សុខុម ដែលធ្វើឲ្យរំភើបចិត្តក្នុងក្រុងទាំងនោះ ។

ក្រុងប៉ារីស គឺជាស្ថានដ៏ស័ក្តិសម ព្រមទាំងមានស្ត្រីទាំងឡាយប្រកបដោយរូបឆោមលោមពណ៌យ៉ាងឆើត ជាដំបន់ដែលពួកអ្នកមេគំនិតអ្នកប្រាជ្ញខាងទស្សនវិជ្ជា ពួកជាងរចនាការ នឹងក្រុមអ្នកនិពន្ធតែងមករកអាហារសម្រាប់ខួរក្បាល រកមហាជនដើម្បីសង្កេត រកមិត្តសំឡាញ់ដើម្បីជ្រើសរើសយក ។

នៅក្រុងវីយែន អ៊ីស្មាអ៊ីលកើតមានសេចក្តីស្រងូតស្រងាត់ រលឹកដល់ស្រុកកំណើត ព្រោះក្រុងនេះមានសណ្ឋានស្រងេះស្រងោចពេក ដោយមានផ្ទះកំពូលស្រួចនឹងទន្លេវេចវៀន ចំណែកនៅក្រុងឡុងនឹងក្រុងប៊ែរឡាំង អ៊ីស្មាអ៊ីលបានស្គាល់នូវអាការភាពនៃពួកក្រុមហ៊ុនជាតិអឺរ៉ុបផ្លូវពាណិជ្ជកម្ម សិប្បិយការ ឬក្រុមរាជាធិបតេយ្យ តាំងនៅជាគណៈៗក្នុងទីបិទបាំងយ៉ាងមាំ ។ គឺទីនោះហើយដែលពួកមនុស្សមានត្រកូល

មុខក្រហមដូចឥដ្ឋ ឬពួកដុកទ័រ (បណ្ឌិត) មុខក្រហមដូចមីសំទើបនឹងកាប់ថ្មីៗ យកស្រាប៊ីយែរ ស៊ុព នឹងល្បែងបៀរជាប្រមាណ នាំគ្នាជំនុំអំពីកិច្ចការរាជការ អំពីប្រស្នាប្រាក់កាស នយោបាយ ផ្លូវសេដ្ឋកិច្ច នឹងបញ្ហាយ៉ាងសំខាន់ៗ ទាំងពួងតាមរបៀបវិធានការរាល់ថ្ងៃ ។

លុះមកដល់ស្រុកឡាតាំង មុនដំបូង អ៊ីស្មាអ៊ីលងឿងឆ្ងល់នឹងរបៀបដ៏សុខុមនឹងសេចក្ដីគួរសមរបស់អ្នកស្រុកចំពោះពួកស្រីៗ តែដល់ទៅប្រទះឃើញប្រទេសអ៊ីតាលី នឹងអេស្ប៉ាញ ក៏ធ្វើដូចគ្នាដែរ រឿងនេះបណ្ដាលឲ្យអ្នកកំឡោះគិតពិចារណាហើយយល់ថា ការណ៍រាប់អានឥត្ថិភាពដូចជាប្រទេសអារ៉ាប់ ដែលបានទុកស្រីដូចជាវត្ថុជាគ្រឿងលំអមកជាយូរឆ្នាំហើយ នោះមិនមែនទាស់ទេ សាសនាណាដែលធ្វើបែបនេះ គេទុកសាសនានោះជាមានអារ្យធម៌យ៉ាងពិតប្រាកដ ។

កាលវិលមកស្រុកកំណើតវិញ អ៊ីស្មាអ៊ីលនៅកាន់តាមទំនៀមទម្លាប់នៃប្រទេសអឺរ៉ុបខ្លះដែលជាទំនាស់នឹងជាទំនៀមប្រទេសអារ៉ាប់ ៗ អ៊ីស្មា-អ៊ីលលះបង់សំលៀកបំពាក់សំរាប់ជាតិអារ៉ាប់អស់ ដូចយ៉ាងខោទូលាយស្បិទ្រ មួកក្រឡុមជាត្បូងស្លេកស្លះ សំពត់រយ៉េរយ៉ៃសម្រាប់វណ្ណនឹងឆ្ពតជួតសំពោងពីលើដូចជាប៉ម ៗ រ៉ក្រឡប់ជាស្លៀកពាក់របៀបល្បែងកីឡា (ស្ព័រ) សំពត់សាខ្លាតអង់គ្លេសទន់នឹងសមរម្យ គឺខោខ្លីពាក់ស្រោមជើងស្បែកយ៉ាងទន់ពីក្រៅ ថែមអាវទ្រនាប់សំពត់សាច់ម៉ដ្ឋ ហើយស្តើងស្រាលដែលនាំឲ្យត្រជាក់កាយស្រួល ៗ (មានត)

# ការប្រឡងប្រជែងទំនៀមទម្លាប់ខ្មែរ

ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ

ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ នៅពុទ្ធសាសនបណ្ឌិត្យ ក្រុងភ្នំពេញ ត្រូវការជ្រើសរើសយកឯកសារទំនៀមទម្លាប់ខ្មែរ ដោយបើកការប្រឡងប្រជែង ២ រឿង គឺ

រឿងទី ១ អំពីរាំបា

រឿងទី ២ អំពីការស្លាបជាគ្រឹះស្ថាន

ឯកសារសម្រាប់ប្រឡងនេះ សម្រេចយកនៅឆមាសទី ១ គឺតាំងពីខែមករា ដល់ដាច់ខែមិថុនា ឆ្នាំ ១៩៥៤ ។

ដូច្នេះ អស់លោកទាំងឡាយ ទោះជាស្ត្រី បុរស គ្រហស្ថ ឬ បព្វជិត ដែលស្ម័គ្រចិត្តជាបេក្ខជនប្រឡង សូមតែងរឿងដូចខាងលើ ជូនទៅក្រុមជំនុំទំនៀមទម្លាប់ខ្មែរ ឲ្យទាន់មុនបើដាច់ខែមិថុនាឆ្នាំ ១៩៥៤ ។

បេក្ខជនទទឹងយករឿងប្រឡងទៅជូនផ្ទាល់ខ្លួនក៏បាន, ផ្ញើតាមប៉ុស្តិ៍ទៅក៏បាន, យកទៅជូនសាលាឃុំ ឬសាលាស្រុកឲ្យផ្ញើឲ្យក៏បាន ដោយកាខ្ទង់សំបុត្រថា:

ជូនដល់ ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ នៅពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

រឿងដែលបានជាប់លេខ នឹងបានរង្វាន់ជា ៤ ថ្នាក់ គឺ

រង្វាន់លេខ ១ ..... ៤០០៛. ០០

រង្វាន់លេខ ២ ..... ៣០០, ០០

រង្វាន់លេខ ៣ ..... ២០០, ០០

រង្វាន់លេខ ៤ ..... ១០០, ០០

បេក្ខជនមួយរូបៗ អាចតែងតាំង២រឿងបាន, តែសូមសរសេររឿងមួយធ្វើជាឯកសារមួយដាច់ដោយឡែកពីគ្នា ដោយដាក់ឈ្មោះឯកសារ ឈ្មោះបេក្ខជន ព្រមទាំងទីលំនៅឲ្យប្រាកដលើឯកសារនីមួយៗ ។

មួយរូបៗ បើតែងល្អទាំង ២ រឿងនឹងបានជាប់លេខ បានរង្វាន់ទាំង ២ រឿង ។

ឯសំនួរខាងមុខនេះ ចួនកាលបេក្ខជនឆ្លើយពុំបានសព្វគ្រប់ទេ ប៉ុន្តែបើបេក្ខជនឃើញការឯទៀតក្រៅពីនេះ ហើយអាចសរសេរឲ្យការទៅបាន នោះក្រុមជំនុំអរគុណណាស់ ពីព្រោះសំនួរទាំងប៉ុន្មាននេះគ្រាន់តែជាលំនាំត្រាយផ្លូវអ្នកតែងទេ, ឯការធំបំផុត គឺ ក្រុមជំនុំត្រូវការតែឯកសាររបស់បេក្ខជនណា ដែលឲ្យការច្រើនហើយមានគោលចារិកសព្វគ្រប់ ។

# គោលនៃការតែងរឿងប្រឡង

## រឿងទី ១ អំពីរាហូ

ក្នុងបច្ចុប្បន្នកាលនេះ យើងតែងឃើញមានរូបរាហូច្រើនជាអនេក នៅលើជញ្ជាំងប្រាសាទបុរាណ នឹងនៅទីវត្តនានារបស់ខ្មែរយើងក្នុងកម្ពុជរដ្ឋ ។ ការនេះបង្ហាញឲ្យឃើញថា ប្រជាជនខ្មែរយើងធ្លាប់ជឿធ្លាប់គោរពរាហូអំពីអតីតកាល ។

ហេតុនេះ បានជាក្រុមជំនុំទំនៀមទម្លាប់ខ្មែរដែលជាអ្នកស្រាវជ្រាវរកទំនៀមខ្មែរត្រូវការប្រមូលឯកសារផ្សេងៗ ដែលទាក់ទងដោយរាហូ ដូចមានសំនួរតទៅនេះ :

ក ) រូបរាហូដែលគេត្រូវការគូរ ឬឆ្លាក់នៅប្រាសាទ ឬនៅវត្ត តើគេតែងគូរដាក់ត្រង់ណាខ្លះ? ប្រយោជន៍អ្វីបានជាគេគូរដាក់ត្រង់នោះ?

ខ ) គេមានគូរឬឆ្លាក់រូបរាហូនៅទីណាខ្លះទៀតក្រៅពីប្រាសាទ ឬវត្តដែរឬទេ ?

គ ) នៅសួរគ៌ាល័យ ឬ ក្នុងការម្ឈូស តើគេមានគូរ ឬ ឆ្លាក់រូបរាហូទេ ? បើមានធ្វើនៅត្រង់នោះ តើប្រយោជន៍អ្វីបានជាគេធ្វើ? ដោយមានទំនៀមដូចម្តេច ?

ឃ) ប្រយោជន៍អ្វីបានជាគេគូរឬឆ្លាក់រូបរាហូដាក់ក្នុងផ្ទះ នឹងក្នុងព្រះរាជវាំង?

ង ) កាលគេទឹងគូរឬទឹងធ្លាក់រូបកហូ តើមានក្បួនខ្នាតនិយាយយ៉ាងណាខ្លះដែរឬទេ? ហើយគេគូរឬធ្លាក់ធ្វើទម្រង់មុខ, ធ្វើសក់, ធ្វើធ្មេញ ។ល។ គេឲ្យពណ៌បែបណា? ។ល។

ច ) កាលគេទឹងចាប់ផ្តើមគូរឬធ្លាក់ឬទឹងបង្ហើយកិច្ចនេះ តើមានទំនៀមធ្វើពិធី (សំណែន បូជា ត្រណម) ។ល។ ដែរឬទេ?

ឆ ) មានឈ្មោះផ្សេង ៗ សម្រាប់ហៅជំនួសឈ្មោះកហូឬទេ ?

ជ ) ហេតុដូចម្តេចបានជាគេធ្វើរូបកហូតែ ១ កំណាត់ខ្លួន ?

ឈ) មានរឿងព្រេងទាក់ទងដោយកហូដែរឬ ?

ញ ) ក្បួនបោរ កហូមានតំណែងជាអ្វីខ្លះ ?

ដ ) បើមានជំនឿឬពិធីអ្វីទាក់ទងដោយកហូ សូមបរិយាយ ។

---

## រឿងទី ២ អំពីការស្ថាបនាគ្រឹះស្ថាន

### ការសង់ផ្ទះ:

ក ) សណ្ឋានទ្រង់ទ្រាយផ្ទះខ្មែរយើង មានឈ្មោះប៉ុន្មានយ៉ាង? ផ្ទះរោងដោល, រោងឡើង, ប៉ិត, កន្តាំង, ។ល។ មានទ្រង់ទ្រាយប្លែកពីគ្នាដូចម្តេចខ្លះ? (បើអាចគូររូបភាពផ្ទះទាំងនោះបាន សូមគូរដោយទឹកខ្មៅឲ្យមានសរសៃច្បាស់ៗ ដោយដាក់ខ្នាតទទឹងបណ្តោយជាដើមផង) ។

ខ) រដូវកាលណាគេធ្វើផ្ទះបែបណា ?

គ) ផ្ទះនីមួយៗ មានល្វែងប៉ុន្មាន? ថ្នាក់ប៉ុន្មាន? ហើយល្វែងណាសម្រាប់ដាក់អ្វី? ថ្នាក់ណាសម្រាប់ធ្វើអ្វី?

ឃ) ផ្ទះមានឈ្មោះជាមួយគ្នា តើគេបែងចែកគ្នាទៅតាមជនបទដែរឬ?

ង) កន្លែងភូមិភាគនីមួយៗ តាមទំនៀមគេសង់ផ្ទះធំ, ផ្ទះប្រាយ, ជង្រុកស្រូវត្រង់ភាគណា ? អណ្តូងទឹកត្រង់ភាគណា ? ។ល។

ច) ផ្ទះគ្រឿងឈើក្តី - ឥដ្ឋក្តី - ស៊ីម៉ងត៍ក្តី វេលាផ្តើមប្រុង ដូចលើកសសរឬរៀបឥដ្ឋដំបូង តើគេចាត់របៀបនីងពិធី (សំណែន បូជា ត្រណម) ។ល។ ដូចម្តេចខ្លះ?

ឆ) នៅពេលសង់ផ្ទះ ប្រយោជន៍អ្វីបានជាគេដាក់សំពត់ជាតិ ១ ផ្ទាំងនៅមេដំបូល? ជាតិនោះគេធ្វើយ៉ាងណា?

ជ) នៅពេលឡើងផ្ទះ តើគេធ្វើពិធីដូចម្តេចខ្លះ?

## ការសាងវត្ត:

ក) ខាងវត្តនីមួយៗដែលសាងថ្មី តើត្រូវធ្វើទទឹងបណ្តោយប៉ុណ្ណា? ហើយទទឹងបណ្តោយបែរទៅខាងណា ?

ខ) សណ្ឋានទ្រង់ទ្រាយវិហារ សាលា កុដិ ។ល។ ដូចម្តេចខ្លះ? មានឈ្មោះប៉ុន្មានយ៉ាង? (បើអាចគូររូបភាពអចលនវត្ថុទាំងនេះបាន សូម

គួរដោយទឹកខ្មៅឲ្យមានសរសេរច្បាស់ៗ ដោយដាក់ខាតទទឹងបណ្ដោយជាដើមផង ) ។

គ ) សណ្ឋានទ្រង់ទ្រាយវិហារ សាលា កុដិ មានប្លែកគ្នាដោយរដ្ឋកាលដែរឬទេ ?

ឃ ) គ្រឿងរបទាំងប៉ុន្មានខ្លះដែលគេតែងធ្វើដាក់វត្ត ? ហើយគ្រឿងណាគេធ្វើតំណាងអ្វី ?

ង ) ក្នុងភាគផែនទីវត្តនីមួយ ៗ តើគេត្រូវធ្វើវិហារត្រង់ណា ? សាលាបុណ្យត្រង់ណា ? កុដិចៅអធិការត្រង់ណា ? ។ល។ ( បើមានក្បួនណានិយាយពីការបែងភាគនេះសូមកត់ទៅផង ) ។

ច ) ការសាងទីវត្តទាំងមូលក្ដី ការសង់វិហារក្ដី សាលាបុណ្យក្ដី កុដិក្ដី ។ល។ មានពិធីប៉ុន្មានថ្នាក់ ? ដូចថ្នាក់ប្រងដំបូង, ថ្នាក់លើកសសរ, ថ្នាក់លើកជហ្វា, ថ្នាក់ឆ្លង, ថ្នាក់ឡើងកុដិ, តើមានរបៀបទំនងពិធី ( សំណែន បូជា ត្រណម ) ដូចម្ដេចខ្លះ ?

ឆ ) ហេតុអ្វីបានជាគេធ្វើខ្មអក្នុកតាដាក់ពីមុខវត្តពល់តែវត្ត ? តើគេធ្វើតាមជំនឿអ្វី ? មានប្រយោជន៍អ្វីបានជាគេធ្វើ ? ក្នុងកិច្ចសាងវត្តតើខានធ្វើខ្មមនេះបានឬពុំបាន ?

បណ្ដាឯកសារសម្រាប់ប្រឡងទាំង ២ មុខ ដូចរៀបរាប់ក្នុងសំនួរខាងលើនេះ បើបេក្ខជនត្រូវការតែងឯកសារមុខណា សូមកុំភ្លេចប្រាប់ដើមកំណើតអត្ថបទក្នុងឯកសារមុខនោះ ថាធ្វើតាមគម្ពីរឬក្បួនណា, តាមពាក្យនរណា, ឬបានឃើញគេធ្វើនៅទីណា ។ល។

ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ